# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៦ ខែសីហា លេខ ៨

ព.ស. ២៤៩៧ – គ.ស. ១៩៥៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

*ផ្នែកសាសនា* — បញ្ជីរឿង — ទំព័រ

— មាតាបិតុគុណកថា . . . . . . . . . . . ព្រះញាណកោសល ញាណ-ឈិន ៥៦៣
— សមភាពក្នុងព្រះពុទ្ធសាសនា . . . . . . . . . ឃុនបណ្ណានុរ័ក្ស ប៊ូ-ប៉ូ . . . . . ៥៧៨
— បញ្ញាសជាតក ភាគទី ២ (តមក) . . . . បណ្ឌិតមហា ឈឹម- ស៊ុម . . . . ៥៩៦

*ផ្នែកអក្សរសាស្ត្រ*

— រឿងសៅរ៍សោយ (តមក) . . . . . . . . ព្រះមហាឧត្ដមវិជ្ជា ប៊ុំង- ប៉ម . . . ៦០៦
— រឿងសាមកុក (តមក) . . . . . . . . . . ឧកញ៉ា នូ- កន . . . . . . . . . ៦១១
— ទាលៈនឹងទមយន្តី (តមក) . . . . . . . . អ្នកស្រី ស៊្រុន-សារិយ៉ាន់ . . . . ៦១៥
— ដំណឹងតាមខ្យល់ក្នុងកគ្គារៈ (តមក) . . . . លោក ផេង - ជ្រីវ . . . . . . . . . ៦១៩
— សកម្មភាព នៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ
បរិយាយពីការសាងភិលុកចេតិយ . . . . លោក ជាប - ពិន . . . . . . . ៦២៣

*កំណត់នឹងព្រឹត្តិការណ៍*

— ពិធីបុណ្យបញ្ចុះបឋមសិលា នៅទីស្ថាបនា
ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ . . . ពុទ្ធសាសនបណ្ឌិត្យ . . . . . . . . ៦៣៤

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES


PARTIE RELIGIEUSE: Page

— Matapitugunakatha . . . . . *Vén.* NHEAN-CHHOEUN . . . 563
— L'égalité d'après la religion Bouddhique . . . . . . . . M BOU-PO . . . . . . . . . 578
— Pannasajataka vol-II (suite) . M. CHHIM-SOUM . . . . . . 596

PARTIE LITTERAIRE:

— Le « SAU-SOY » ou l'influence saturnienne (suite) . . . . . *Vén.* PEUNG-PAM . . . . . . 606
— Histoire de Samkok (suite) . . *Oknha* NOU-KAN . . . . . . 611
— Nala et Damayanti (suite) . . . *Mme* SRIN-SARIS-YANN . . . 615
— Le souffle du désert (suite) . M. PHENG-CHRIV . . . . . . 619
— L'activité de la Commission des Mœurs et Coutumes . . . . M. CHAP-PIN . . . . . . . . 623

NOTES ET CHRONIQUES:

— La pose de la 1e pierre à l'Université Bouddhique «PREAH SIHANOUK» . . . . . . . INSTITUT BOUDDHIQUE . . . 634


Prix d'abonnement annuel (comprenant 12 numéros) 200$00

# មាតាបិតុគុណកថា

## ព្រះញាណកោសល ញាណ-ឈឹន

ទេសនាក្នុងពិធីបុណ្យ ជីវិកភត្តទាន របស់លោកឧកញ៉ានាយកមន្ត្រី ឃឹន-ប៊ឹម អ្នកគ្រប់គ្រងពុទ្ធសាសនបណ្ឌិត្យ ដែលធ្វើជូនមាតាបិតាក្នុងគេហស្ថាន កាលពីថ្ងៃសៅរ៍ ៧ រោច ខែចេត្រ ឆ្នាំមមីឆស័ក ព.ស. ២៤៩៧ (២៤-៤-៥៤)

---

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

អាត្មាភាពសូមចំរើនពរ ៤ ប្រការគឺ អាយុ, វណ្ណៈ, សុខៈ, ពលៈ ចំពោះពួកពុទ្ធបរិស័ទទាំងឡាយ, ក្រែងអាត្មាភាពសំដែងទៅហើយមានក្តាំងក្តាត់ ឬ ផ្គាំផ្គងពាក្យពេចន៍ក្នុងពេលសំដែងសូមខន្តីអភ័យទោស, អាត្មាភាពសូមស្រង់យកពាក្យប្រកាសរបស់លោក បាប-ពិន អម្បាញ់មិញ ត្រង់ដែលថា មតកភត្តទាន និង ជីវិកភត្តទាននោះ មកសំដែងជាធម៌ទេសនាតទៅ ដើម្បីឲ្យសមរម្យដល់ពិធីបុណ្យ ដែលលោកទានិស្រពធិបតីព្រមទាំងក្រុមញាតិកំពុងចាត់ចែងនេះ ដ្បិតបុណ្យបែបនេះ លុះតែសប្បុរសអ្នកមានសទ្ធាជ្រះថ្លាមោះមុត ចំពោះគុណលោកអ្នកមានគុណ ទើបអាចបរិច្ចាគធនធានធ្វើទៅកើត បើមានសន្តានចិត្តស្អាក់ស្ទើរមិនជឿស៊ប់ទេ ក៏មិនអាចនឹងបរិច្ចាគបានឡើយ ។

ពាក្យថា "មតកភត្តទាន" គឺធ្វើទានឧទ្ទិសផលជូនចំពោះបុព្វការីជនដែលចែកស្លានទៅកាន់បរលោកនាយ, ពាក្យថា "ជីវិកភត្តទាន"

គឺធ្វើទានឧទ្ទិសផលជូនចំពោះបុព្វការីជន ដែលកំពុងមានជីវិតរស់នៅសព្វថ្ងៃ ។

បណ្ដាបុណ្យទាំងពីរប្រការនេះ មតកភត្តទាន ធ្លាប់ឃើញគេធ្វើរឿយ ៗ ចំពោះវេលាដែលមានញាតិទទួលមរណៈថ្មី ៗ ឬយូរហើយ, ឯជីវិតកភត្តទាន យូរ ៗ ទើបមានម្ដង ព្រោះអ្នកដែលមានជីវិតរស់នៅគេពុំសូវនឹកនាដល់ ទោះបីមាននឹកដល់ខ្លះហើយធ្វើ ក៏ច្រើនគេហៅថាធ្វើបុណ្យឆាក ឬបុណ្យវេរបច្ច័យ ៤ ទៅវិញ គេមិនហៅថាបុណ្យជីវិតកភត្តទានទេ ព្រោះពាក្យនេះគេមិនធ្លាប់ហៅ; តែតាមការពិត បុណ្យឆាកឬបុណ្យវេរបច្ច័យ ៤ ក៏គឺបុណ្យជីវិតកភត្តទាននោះឯង ។

វេលានេះ អាត្មាភាពសូមសំដែងអំពីបុគ្គលរកក្រក្នុងលោកជាមុនសិនរួចហើយសឹមត្រឡប់មកសំដែងបញ្ចប់ពាក្យថាជីវិតកភត្តទាននេះ ជាខាងក្រោយ ។

ព្រះពុទ្ធដីកាក្នុងព្រះសុត្តន្តបិដក អង្គុត្តរនិកាយទុកនិបាតថា ទ្វេមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា ទុល្លភា លោកស្មឹំ ប៉ុណ្ណោះ ជាដើម ប្រែថា "ម្នាលភិក្ខុទាំងឡាយ! បុគ្គលពីរពួកនេះ រកបានដោយក្រក្នុងលោក" ។ កតមេ ទ្វេ 'បុគ្គលពីរពួក តើអ្វីខ្លះ? បុគ្គលពីរពួកនោះគឺ បុព្វការីបុគ្គល (បុគ្គលអ្នកធ្វើឧបការមុន) ១ កតញ្ញូ

កតវេទីបុគ្គល (បុគ្គលអ្នកដឹងឧបការគុណដែលគេធ្វើចំពោះខ្លួនហើយធ្វើតបគុណវិញ) ១ ទាំងពីរពួកនេះ រមែងរកបានដោយក្រក្នុងលោក ” ។

ហេតុម្តេចបានជាបុគ្គលពីរពួកនេះ គេរកបានដោយក្រក្នុងលោក? បានជាគេរកបានដោយក្រក្នុងលោក ព្រោះបុព្វការីបុគ្គល ដូចមាតាបិតា កម្រនឹងមានព្រហ្មវិហារធម៌ទាំង ៤ នឹងសង្គហធម៌ទាំង ៥ ពេញលេញទៅលើបុត្តធីតា ច្រើនតែបាននេះខ្វះនោះ ។ ចំណែកកតញ្ញូកតវេទីបុគ្គល ដូចបុត្តធីតា ក៏កម្រនឹងធ្វើកិច្ចតបគុណលោកវិញ ឲ្យបានពេញបរិបូណ៌ តាមស្ថាន ៥ យ៉ាង ។

មួយទៀត បុព្វការីបុគ្គល នឹងកតញ្ញូកតវេទីបុគ្គល ជាអ្នកប្រតិបត្តិការតាមធម៌ស្មើគ្នាទៅវិញទៅមកនោះ កម្រនឹងមាន ច្រើនតែបានម្ខាងខ្វះម្ខាង គឺបើមាតាបិតាមានព្រហ្មវិហារធម៌នឹងសង្គហធម៌ទៅលើបុត្តធីតា ៗ បែរជាមិនមានធ្វើកិច្ចតបគុណលោក ឬមាតាបិតាមិនមានធម៌គ្រប់គ្រាន់ទៅលើបុត្តធីតា ៗ ត្រឡប់ជាមានធម៌គ្រប់គ្រាន់ទៅរកមាតាបិតា; អាស្រ័យហេតុនេះ បុព្វការីបុគ្គល នឹងកតញ្ញូកតវេទីបុគ្គល ទើបបាត់ជាបុគ្គលរកក្រក្នុងលោក ។ សូមសាធុសប្បុរសទាំងឡាយ ចាំស្តាប់អាត្មាភាពនឹងអធិប្បាយតទៅនេះ ។

ធម្មតា បុព្វការីបុគ្គល តួយ៉ាងមាតាបិតាលោករមែងធន់ទ្រាំអត់ស-ស្រេកកំលាន អត់ទ្រាំការក្តៅត្រជាក់ អត់ទ្រាំការគ្រាំគ្រារបស់បុត្តធីតា

ពុំប្រកាន់ទោស ថែមទាំងពុំធុញទ្រាន់ក្នុងការព្យាបាលបុត្តធីតាឡើយ ហើយក្រាលព្រហ្មវិហារធម៌ទៅលើបុត្តធីតាសព្វទិវារាត្រី តាំងពីពេលដែលបានជ្រាបថាទារកមកចាប់ផ្ទៃដរាបដល់កើតឡើង នេះហើយជាឧបការគុណយ៉ាងធ្ងន់ខ្ពង់ខ្ពស់ឥតគូទឹងប្រៀបផ្ទឹមបាន មានតែកម្រាស់ប្រឹថពី ជម្រៅមហាសមុទ្រ កំពស់ភ្នំព្រះសុមេរុ ជាគ្រឿងឧបមានុបមេយ្យប៉ុណ្ណោះ ។ ចំពោះសង្គហធម៌វិញ មាតាបិតាតែងបំពេញធម៌ ៥ ប្រការគឺ

១ – ហាមប្រាមបុត្តធីតា មិនឲ្យប្រព្រឹត្តអំពើអាក្រក់សព្វយ៉ាង មានហាមមិនឲ្យធ្វើវេរ ៥ ជាដើម,

២ – ដឹកនាំពន្យល់បុត្តធីតាឲ្យជ្រះថ្លា ឲ្យតាំងនៅក្នុងគុណដ៏ល្អគ្រប់ជំពូក ដូចការស្វែងរកប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍បរលោក ដោយខានពុំបាន មានបំពេញកុសលជាដើម,

៣ – ដឹកនាំពន្យល់បុត្តធីតាឲ្យសិក្សាវិជ្ជាសាស្ត្រទាំងផ្លូវលោក ផ្លូវធម៌ ឧបត្ថម្ភប្រដាប់សម្រាប់រៀន សំលៀកបំពាក់ និងអាហារូបករណ៍តាមឋានៈរបស់ខ្លួន,

៤ – លុះបុត្តធីតាចំរើនវ័យវឌ្ឍនាហើយ ក៏ចែកសវិញ្ញាណកទ្រព្យខ្លះ អវិញ្ញាណកទ្រព្យខ្លះ តាមមានតាមបាន ដើម្បីទុកជាកិត្តិយសជាទីលើក,

៥ – រៀបចំអាពាហ៍វិវាហមង្គលឲ្យបុត្តធីតាមានគ្រួសារ តាមត្រកូលដែលសមគួរ ។

សង្គហធម៌ទាំង ៤ ប្រការនេះសុទ្ធតែជាឧបការគុណដ៏ជ្រាលជ្រៅទូលំទូលាយផុតវិស័យនៃជនដទៃនឹងអាចធ្វើត្រាប់បាន ។

មិនត្រឹមតែប៉ុណ្ណោះ ទោះទាំងជំនូនទានដ៏ជ្រាលជ្រៅគម្ពីរភាពនឹងអាថ៌កំបាំងទាំងប៉ុន្មាន ដែលជាប់ទាក់ទងដោយផ្លូវបំរើន ក្នុងឥធលោកបរលោក សឹងនាំយកមកលាតត្រដាងចង្អុលប្រាប់បុត្តធីតា ដូចពាក្យថា កូនអើយ! ការចាយវាយទ្រព្យខ្ជះខ្ជាយពុំសមហេតុផល យូរៗទៅក៏គង់នឹងវិនាសហិនហោចពុំខាន ដូចថ្នាំសម្រាប់បន្តក់ភ្នែក, ទឹកព្រែកត្រូវនាច, ដុំសាច់ក្នុងអំបែងក្តៅ, អម្បិលត្រូវទឹកជាដើម ហេតុនោះ កូនកុំប្រមាទឲ្យសោះ, ឯការសន្សំទ្រព្យត្រូវទំនងសមតាមហេតុផលវិញ តែងបានលូតលាស់ចំរុងចំរើនកពូនឡើងរៀងរាល់ថ្ងៃ ដូចមេឃ្មុំ, មេកន្ទ័ ពាំកេសរផ្កាមកធ្វើសំបុកធ្វើទឹកឃ្មុំ, ចាប់ធ្វើសំបុក, កណ្ដៀរពូនដោក, ទឹកតោតកក្នុងបំពង់, ទឹកព្រែកជន់ជោរដូច្នោះដែរ ហេតុនោះ កូនត្រូវសំចៃទ្រព្យ ។

ជំនូនទានដ៏ថ្លៃថ្លាព្រោះប្រាជ្ញាប្រយោជន៍ចំពោះបុត្តធីតានេះ សឹងជារឿងនៃព្រហ្មវិហារធម៌របស់បុព្វការីបុគ្គល ផ្សាយទៅលើបុត្តធីតាទាំងឡាយ ។ តែមានជនជាមាតាបិតាខ្លះ កាលទារកមកចាប់ផ្ទៃ បែរជារកថ្នាំមកផឹករំលូតចោលចេញ, ខ្លះដល់ទារកប្រសូតមក យកទៅកប់ចោលទាំងរស់, ខ្លះគ្រាន់តែចិញ្ចឹមឲ្យរស់ គ្មានទំនុកបំរុងតាមសង្គហធម៌

ទាំង ៥ ម៉្យាងហើយបុត្តធីតានោះទៅជាល្ងីល្ងើ ស្មើគ្នានឹងសត្វ ជាមនុស្សខ្វះវិជ្ជា ខ្វះទ្រព្យសម្បត្តិ ខ្វះធម៌ក្នុងខ្លួន ។ ហេតុនោះ បុព្វការីបុគ្គលទើបលោកចាត់ថា ជាបុគ្គលរកបានដោយក្រក្នុងលោក ។

ឯកតញ្ញូកតវេទីបុគ្គលវិញ ត្រូវយ៉ាងដូចបុត្តធីតាត្រូវជាអ្នកទទួលស្គាល់ទម្ងន់ឧបការនោះៗ ហើយតាំងចិត្តដូច្នេះថា អាត្មាត្រូវតែធ្វើតបឧបការទឹងអាក់ខានមិនបាន ហើយស៊ូទ្រាំធ្វើការតបស្នងពេញកម្លាំង មិនបណ្តែតបណ្តោយឲ្យចិត្តលង់ទៅក្នុងអំណាចអវិជ្ជា គឺការមិនដឹងគុណនោះឡើយត្រូវតែប្រតិបត្តិតបឧបការធម៌របស់លោក ឲ្យពេញលេញវិញដោយស្ថាន ៥ យ៉ាង ដូច្នេះ

១ - អាត្មាត្រូវតែចិញ្ចឹមលោកវិញ,

២ - អាត្មាត្រូវតែធ្វើកិច្ចជំនួសលោកវិញ,

៣ - អាត្មាត្រូវតែរក្សាវង្សត្រកូលលោកឲ្យល្អ,

៤ - អាត្មាត្រូវតាំងខ្លួនទុកក្នុងគុណធម៌ សមគួរជាអ្នកទទួលទ្រព្យមត៌កបាន,

៥ អាត្មាត្រូវតែធ្វើទក្ខិណាទានជូនចំពោះលោកទាំងកំពុងមានជីវ-ភាពនឹងមរណភាពទៅហើយ ។

បុត្តធីតា មិនត្រឹមតែត្រូវធ្វើតបដោយបច្ចុប្បន្នធម៌ទាំង ៥ ប្រការប៉ុណ្ណោះឡើយ ត្រូវធ្វើតបដោយឧបការធម៌ជាន់ខ្ពស់ ៤ យ៉ាងដទៃទៀតគឺ

ត្រូវញុំាងមាតាបិតាឲ្យមានសទ្ធា ឲ្យមានសីល ឲ្យមានចាគៈ ឲ្យមានបញ្ញា ឲ្យសមដល់ទម្ងន់ព្រហ្មវិហារធម៌របស់បុព្វការីជនទាំងនោះ ។

មានបុត្តធីតាខ្លះ កន្លងលោកប្រកបដោយអវិជ្ជា ជាអ្នកវង្វេងមិនដឹងគុណ មិនធ្វើតបគុណ គឺធ្វើសន្តានព្រងើយៗ មិនទឹកនា មិនគោរពគុណលោក បែរជាប្រវត្តចិត្តទៅទីដទៃ ៗ មិនសមដល់តម្លៃទឹកចិត្តរបស់លោកដែលអន្ទោលទៅរកបុត្តធីតា សមដូចបុរាណកាសិតថា "ម្ដាយរឭកកូនដូចចង្វាប្រដេញ កូនរឭកម្ដាយវិញដូចព្រះប្រែក្រោយ" ប៉ុណ្ណេះជាដើម ។ ព្រោះហេតុនោះ ទើបកតញ្ញូកតវេទីបុគ្គល គេរកបានដោយក្រកន្លងលោក ។

មួយទៀត កតញ្ញូកតវេទិតាធម៌មិនមែនជាធម៌ដទៃទេ ពិតជាធម៌របស់អ្នកប្រាជ្ញ ដ្បិតអ្នកប្រាជ្ញត្រូវមានអង្គធម៌ ៤ យ៉ាងជាគ្រឿងទ្រទ្រង់សម្រាប់ចង្អុលបង្ហាញឲ្យឃើញជាក់ស្ដែងកន្លងប្រជុំជន; មិនចាំបាច់តែបុគ្គលអ្នកចេះដឹងសព្វវិទ្យា ជាលោកិយនិងលោកុត្តរៈ ទើបហៅថាអ្នកប្រាជ្ញទេ សូម្បីបុត្តធីតា ដែលមានអង្គធម៌ដូចខាងលើនេះ លោកក៏ហៅជាអ្នកប្រាជ្ញបានដោយពិត ។ ឯអង្គអ្នកប្រាជ្ញ ៤ យ៉ាងនោះគឺ: កតញ្ញូ-កតវេទិតា ១, អត្តសុទ្ធិ ១, បរិសុទ្ធិ ១, សង្គហៈ ១, រួមជា ៤ យ៉ាង ។

ត្រង់ កតញ្ញូកតវេទិតា ជាអង្គទី ១ បានដល់ភាពនៃបុត្តធីតាជាអ្នកដឹងឧបការគុណលោក ហើយធ្វើការដឹងនោះឲ្យជាក់ស្ដែងតបស្នង

ឧបការគុណវិញ ដូចអស់លោកជាទានិស្សរពធិបតីកំពុងចាត់ចែងធ្វើ នេះឯង ។

ត្រង់ អត្តសុទ្ធិ ជាអង្គទី ២ បានដល់ការធ្វើខ្លួនឲ្យបរិសុទ្ធគឺតាំងខ្លួនទុកក្នុងគុណធម៌ថ្លៃថ្នូរ មានមិនសម្លាប់សត្វលួចទ្រព្យគេជាដើមដែលជាអំពើថោកទាបដោយផ្ទាល់ខ្លួន ដូចអស់លោកអ្នកធ្លាប់កប់ប្រសប់កាន់កាប់មកហើយ ។

ត្រង់ បរសុទ្ធិ ជាអង្គទី ៣ បានដល់ការធ្វើឲ្យបុគ្គលដទៃបរិសុទ្ធ គឺមិនគ្រាន់តែតាំងខ្លួនទុកក្នុងគុណធម៌ថ្លៃថ្នូរផ្ទាល់ខ្លួនប៉ុណ្ណោះទេ ត្រូវដឹក-នាំពន្យល់អ្នកដទៃឲ្យតាំងនៅក្នុងគុណធម៌ដូចខ្លួនផងដែរ ។

ត្រង់ សង្គហៈ ជាអង្គទី ៤ បានដល់ការសង្គ្រោះជួយយឹតយោងសណ្តោងឲ្យរួចចាកគ្រោះថ្នាក់ ដោយសង្គហធម៌ ៤ យ៉ាង គឺការបរិច្ចាគទាន ១, និយាយពាក្យពីរោះ ១, ធ្វើការងារជាប្រយោជន៍ជាតិមាតុភូមិទុកជាស្នាដៃ ១, មិនប្រកាន់ឫកពាឆ្មើងឆ្មៃ ១ ។ ឯសង្គហធម៌សម្រាប់គ្រួសារដែលជាប់ទាក់ទងមកក្នុងសិក្ខាលោកទេសត្រនោះ ក៏សឹងសង្គ្រោះចូលក្នុងអង្គទី ៤ នេះដែរ ។

អង្គអ្នកប្រាជ្ញទាំង ៤ យ៉ាង ដូចរៀបរាប់មកដោយទ្រួសៗនេះ សុទ្ធតែជាអំពើអ្នកប្រាជ្ញ ។ ព្រះភគវន្តមុនីសម្មាសម្ពុទ្ធទ្រង់សរសើរអំពើអ្នកប្រាជ្ញនេះណាស់ ទ្រង់សំដែងបន្ទាប់អំពើពាល ត្មះតិះដៀលជនពាល

ហើយទ្រង់លើកដំកើងអំពើបណ្ឌិត សរសើរជនបណ្ឌិត ដូចមានក្នុងមង្គលសូត្រថា "ការមិនគប់រកបុគ្គលពាល គប់រកតែបណ្ឌិតជាមង្គល" ដូច្នេះជាដើម ។

សប្បុរសទាំងឡាយ! អាត្មាភាពសំដែងអំពីបុគ្គលរកបានដោយក្រពីរបំពូកដោយសេចក្ដីបំព្រួញនេះ ដើម្បីជាផ្លូវគំនិតនៃសាធុសប្បុរស ។ បន្ទាប់ពីនេះ នឹងសូមសំដែងសាថយក្រោយវិញ ដើម្បីសំដែងបញ្ជាក់ត្រង់ពាក្យ "ជីវិកកត្ដញ្ញូ" តទៅទៀត ។ ជីវិកកត្ដញ្ញូ គឺធ្វើទានឧទ្ទិសផលជូនបុព្វការីជន គឺមាតាបិតាដែលមានជន្មាយុរស់នៅនាបច្ចុប្បន្ននេះផង ទាំងជូនស្បៀងអាហារ គ្រឿងសំលៀកបំពាក់ ទីដេក ទីនៅសមគួរតាមឋានៈរបស់លោក លុមញ៉ាំងអត្ដភាពឲ្យប្រព្រឹត្ដទៅបានក្នុងកាលសព្វថ្ងៃនេះផង ក៏រាប់ចូលក្នុងជីវិកកត្ដញ្ញូដែរ ។ សេចក្ដីនេះសឹងមានរឿងគោឃាតកបុត្តក្នុងគម្ពីរធម្មបទជាគោលអាង ៖

សេចក្ដីថា មានបុរសម្នាក់នៅជិតក្រុងសាវត្ថីធ្វើរបរចិញ្ចឹមជីវិតខ្លួនឯងនិងគ្រួសារ ដោយការពិឃាតគោ ដើម្បីលក់សាច់តែមួយមុខប៉ុណ្ណោះ តាំងពីក្មេងរហូតដល់អាយុ ៥៥ ឆ្នាំ, ម្ល៉ោះហើយការទទួលទានសាច់គោរាល់ថ្ងៃប៉ុណ្ណោះឆ្នាំនោះ ធ្លាក់ទៅជាសម្ដូស្រញ៉ោមជាប់ចិត្ដនៃគោឃាតកបុរសនោះ ។ ថ្ងៃមួយក្នុងកាលជាខាងក្រោយ គោឃាតកបុរសត្រឡប់មកពីលក់សាច់វិញ បានប្រគល់សាច់១ដុំឲ្យភរិយាធ្វើម្ហូបទទួលទាន ហើយ

ក៏ដើរទៅកាន់កំពង់ទឹក, លុះដួសទឹករួចវិលមក ភរិយាលើកស្ពុកបាយមក ជូនពិសា, ស្រាប់តែពុំឃើញសាច់ គោឃាតកបុរសក៏សួរទៅភរិយាៗ ជំរាបថា “ជនជាសំឡាញ់របស់អ្នកឯង គេថាមានភ្ញៀវទើបនឹងមកដល់ថ្មី គេរកម្ហូបទទួលភ្ញៀវនោះពុំបាន គេមកសួររកសាច់, ខ្ញុំប្រាប់គេថាសាច់ ក្រៅពីនេះទៀតពុំមានទេ, សូម្បីខ្ញុំឃាត់ហាម គេក៏ពុំស្តាប់, សំឡាញ់អ្នកឯងនោះ នៅបេបេសតែកាន់យកសាច់នោះទៅ” ។ គោឃាតកបុរសនិយាយថា “ឯងលើកស្ពុកយកទៅវិញចុះ យើងមិនអាចនឹងបរិភោគបាយដោយឥតមានសាច់គោបានទេ” លុះថាហើយក៏កាន់កាំបិតដើរតម្រង់ទៅកាន់ក្រោលគោខាងក្រោយផ្ទះ ចាប់យកគោមួយមកហើយ លូកដៃទៅក្នុងមាត់គោកាត់យកអណ្តាតគោត្រឹមគល់មកឲ្យភរិយាចំអិន ។ លុះភរិយាចំអិនឆ្អិនស្រេចលើកមកជូនជាថ្មី, គាត់ក៏បរិភោគបាយមួយម៉ាត់ អណ្តាតគោមួយម៉ាត់, វេលានោះ គាត់ទំពាសាច់គោក៏ខាំអណ្តាតរបស់ខ្លួនដាច់ធ្លាក់ចុះមកក្នុងចានបាយមួយរំពេច ដោយអំណាចនៃកម្មជាមហាសាហាវនោះ, មានឈាមស្រក់ហូរស្រោកប្រឡាក់សំពត់អាវ ។ គោឃាតកបុរសស្រែកពេទ់វារដោយជង្គង់ ៤ ដូចគោ មិនយូរថ្ងៃក៏ធ្វើកាលកិរិយាទៅរងទុក្ខក្នុងអវិចិនរក ។ ចំណែកគោ ក្រោយពីគោឃាតកបុរសនោះកាត់អណ្តាតយកទៅ ក៏រងទុក្ខវេទនាមានឈាមហូរហាម ស្រែកពេទ់ទាំងយប់ទាំងថ្ងៃ មិនយូរប៉ុន្មានក៏ក្ស័យជីវិតទៅដែរ ។

កាលគោឃាតកបុរសជិតនឹងស្លាប់នោះ នាងព្រាហ្មណីជាភរិយានិយាយនឹងបុត្រប្រុសរបស់ខ្លួនម្នាក់ថា "នែកូន! មើលចុះបិតារបស់អ្នកវារដោយជន្ទល់ ៤ ដូចគោ ស្រែកពេញទាំងយប់ទាំងថ្ងៃ, សេចក្តីទុក្ខនេះក្រែងធ្លងមកដល់អ្នកផងដែរ? ដូច្នេះអ្នកកុំគិតម្តាយឡើយ ត្រូវអ្នករត់ទៅរកទីណាដែលមានសួស្តីហើយនៅជាសុខចុះ(១) ។ ឯបុត្តហេតុតែខ្លាចសេចក្តីមរណៈ ក៏សំពះលាមាតារត់ទៅកាន់ដែនតក្កសិលា បានចូលទៅរៀនធ្វើការក្នុងផ្ទះនាយជាងមាសម្នាក់ នាយជាងក៏ស្រឡាញ់រាប់អានទុកចិត្តស្មោះអស់ពីដួងហឫទ័យ រហូតដល់លើកធីតារបស់ខ្លួនដែលមានវ័យគ្រប់ការ ឲ្យជាភរិយារបស់គោឃាតកបុត្តនោះ ។

តពីនោះមក ជាងមាសដែលជាបុត្តរបស់គោឃាតកក៏បានលូតលាស់ចំរុងចំរើនដោយភោគទ្រព្យនឹងបុត្តធីតា ។ លុះគាត់ចាស់ជរា ពួកបុត្តធីតានៃជាងមាសនេះ បានរៀនចំណេះវិជ្ជាសិល្បសាស្ត្ររបរជាងមាសស្ទាត់ជំនាញ ហើយក៏ត្រឡប់មកកាន់ក្រុងសាវត្ថីដែលជាមាតុប្រទេសរបស់ជីតាវិញ តាំងគេហដ្ឋាននៅក្នុងក្រុងសាវត្ថីនោះ ។ អាស្រ័យការសេពគប់នឹងសប្បុរស កូនជាងមាសក៏កើតសទ្ធាជ្រះថ្លាមុតមាំក្នុងសន្តាន

---

១ សេចក្តីនេះ គួរនឹងបាប់ថ្នាក់ថា បិតាកំពុងវេទនាជិតនឹងស្លាប់បែរជារត់ចោល ប៉ុន្តែត្រង់នេះប្រហែលព្រះគន្ថរចនាចារ្យលោកស្រួតរួតទៅសំដែងខាងមុខ ត្រង់ដីវិកភត្តទាន ឲ្យជាសេចក្តីពិស្តារវិញ ។

ទើបប្រឹក្សាគ្នាថា "បិតារបស់យើង កាលនៅឯផែនតក្កសិលា លោកមិនដែលបានធ្វើការកុសលអ្វីមួយដែលជាអំពើគាប់ប្រសើរសោះ ឥឡូវលោកមានវ័យចាស់ជរាហើយ" ទើបបុត្តធីតាទាំងនោះជំរាបបិតាថា "បពិត្របិតា! ពួកយើងខ្ញុំជាកូននឹងថ្វាយទានដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ដើម្បីឧទ្ទិសផលជូនដល់បិតា ក្នុងថ្ងៃស្អែកនេះ" ។ លុះព្រឹកឡើង បុត្តធីតាទាំងនោះក៏បានអង្គាសចង្ហាន់ថ្វាយព្រះសម្ពុទ្ធព្រមទាំងព្រះសង្ឃ កាលបើស្រេចភត្តកិច្ចហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគថា "បពិត្រព្រះសុគត! ខ្ញុំព្រះអង្គទាំងឡាយថ្វាយជីវិកភត្តនេះដល់ព្រះអង្គ ដើម្បីសម្រេចផលដល់បិតា; សូមព្រះអង្គធ្វើអនុមោទនាចំពោះបិតារបស់ខ្ញុំព្រះអង្គឲ្យទាន" ។

ព្រះសម្ពុទ្ធក៏ទ្រង់ដាស់តឿនគោឃាតកបុត្ត (ជាងមាស) ដោយព្រះពុទ្ធដីកាថា 'នែឧបាសក! រូបអ្នកចាស់ហើយ មានសរីរៈទុំជោរហើយ ប្រហែលដូចស្លឹកឈើទុំ, ចំណែកកុសលជាស្បៀងក្នុងដំណើរតាមផ្លូវនឹងទៅកាន់បរលោករបស់អ្នកៗ ពុំទាន់មានសោះ ដូច្នេះអ្នកត្រូវប្រញាប់ធ្វើនូវកុសលជាទីពឹងរបស់ខ្លួន, អ្នកត្រូវតាំងខ្លួនជាបណ្ឌិតកុំតាំងខ្លួនជាជនពាលឡើយ" ព្រះអង្គទេសនាទំនងនេះអស់រយៈពីរថ្ងៃ ។ លុះចប់ទេសនា ក្នុងថ្ងៃជាគំរប់ពីរ គោឃាតកបុត្តនោះក៏បានតាំងនៅក្នុងអនាគាមិផល ។

បពិត្រសប្បុរសទាំងឡាយ ! រឿងគោឃាតកបុត្តដែលអាត្មាភាព បាននាំមកដោយសេចក្ដីសង្ខេបនេះ ជាគោលសម្រាប់កាត់បន្ថយការ កើតរឿងធ្លាក់ក្នុងជីវិតកតញ្ញូតាជន ហើយជាលំនាំដ៏ថ្លៃថ្នូរសម្រាប់ពុទ្ធបរិ- ស័ទជន ។

ធម្មតាបុគ្គលក្នុងលោក រមែងបានកប់ប្រសប់ទទួលដំណែងទាំងពីរ គឺ ដំណែងបុព្វការីបុគ្គលនឹងកតញ្ញូកតវេទីបុគ្គលពល់រួមតែតម្រៀសក់ងបាន ឡើយ ។ បុព្វការីបុគ្គលជាអ្នកធ្វើឧបការមុន ។ ឯកតញ្ញូកតវេទីបុគ្គល ត្រូវជាអ្នកធ្វើតបស្នងវិញ ។ តែការណ៍នេះ មិនមែនចេះតែបានសម្រេច លទ្ធផលតាមសមប្រកបទេ ព្រោះថាលុះតែបុគ្គលទាំងពីរក្រុមនេះ មាន បញ្ញាការណេចូនយល់ស្របគ្នា ឬមានបុណ្យភ័ព្វស្មើគ្នា ទើបសម្រេច លទ្ធផលទាំងសងខាងទៅបាន, បើមិនស្របគ្នាហើយ ក៏មិនអាចនឹង សម្រេចផលទៅបានទេ សមដូចសុភាសិតរបស់ដីកាចារ្យថា កាបុត្តា អបុញ្ញកា ជនា ជនអ្នកឥតបុណ្យ តែងបានបុត្តធីតាមិនល្អ កុទាសា អបុញ្ញកា ជនា ជនអ្នកឥតបុណ្យ តែងបានខ្ញុំប្រុសស្រីមិនល្អ ប៉ុណ្ណោះជាដើម ជាន័យសម្រាប់វិនិច្ឆ័យក្នុងរឿងនេះ ។

ក្នុងសម័យនេះ អស់លោកអ្នកជាបុត្តធីតានៃឧបាសិកានាម ប្រុម សង្គ្រោះចូលក្នុងបុត្តធីតាល្អគួរជាទីសរសើរ ព្រោះមានកតញ្ញូកតវេទិតា-

ធម៌ចំពោះមាតា ត្រូវតាមគន្លងអ្នកប្រាជ្ញឥតមានឃ្លៀងឃ្លាត, គួរតែមានសេចក្ដីរីករាយជាតិយោភាព ចំពោះការបរិច្ចាគទេយ្យវត្ថុតបស្នងដ៏ថ្លៃថ្លាក្នុងបច្ចុប្បន្ននេះថា អាត្មាមានលាភបានធ្វើបុណ្យចំលើអគ្គអរហន្ត គឺមាតាដែលកំពុងមានជន្មាយុរស់នៅ ។ ទាំងឧបាសិកានាម ប្រធុមជាមាតាសោក ក៏សង្គ្រោះបួលក្នុងពួកជនអ្នកមានបុណ្យមានជោគវាសនាមួយដែរ ព្រោះបានទទួលបតិការៈ ការតបស្នងដ៏ខ្ពង់ខ្ពស់អំពីបុត្តធីតាទាំងនេះឃើញទាន់ភ្នែក ហើយគួរតែអង្អែលផ្ទៃពោះខ្លួនដោយមនោសញ្ញាប្រាមោជ្ជរីករាយចំពោះការរាផ្ទៃ ថាទីផ្ទៃពោះអញ ពេញជាមានភ័ព្វណាស់ ព្រោះបានកូនមកសុទ្ធតែប្រកបដោយធម៌, ដូចកាលព្រះសិរីមហាមាយាពុទ្ធមាតា ដែលបានស្ដាប់ពាក្យសរសើរពុទ្ធគុណនឹងពាក្យអញ្ជើញព្រះនាងមកស្ដាប់ព្រះអភិធម្ម ឯស្ថានតាវត្តិង្សអំពីសំណាក់សក្កទេវរាជហើយ នាងក៏ស្ញើចស្ញប់ស្ញែងនឹកសរសើរផ្ទៃព្រះនាងថា " ឱហ្ន៎! ផ្ទៃរបស់អាត្មាហៅពេញជាមានលាភមានសំណាងបំផុត បានពព្រះពុទ្ធមួយព្រះអង្គជាអ្នកប្រាជ្ញធ្វើមកក្នុងលោក" ។ ព្រះនាងក៏ត្រេកអរឥតឧបមា ហើយគមនាការមកកាន់ស្ថានតាវត្តិង្សជាមួយនឹងព្រះឥន្ទ្រាធិរាជ នាគ្រានោះឯង ។

មួយទៀត ពុទ្ធាទិបណ្ឌិតតែងសរសើរអ្នកដឹងគុណហើយធ្វើតបគុណនេះជាអនេកបរិយាយ ព្រោះការនេះជាប្រធាននៃកុសលទាំងពួង ដោយមានបទបាលីថា កតញ្ញុតា ធម្មមូលា សេចក្ដីដឹងគុណ ធ្វើតប-

គុណ ជាប្រសើរនៃធម៌ទាំងឡាយ កតញ្ញុតា បជានតា លោកេ សេចក្តីដឹងគុណ ធ្វើតបគុណជាអំពើប្រសើរក្នុងលោក ។ បុរាណបណ្ឌិតទាំងឡាយលោកតែងបំពេញធម៌នេះរៀងរាល់រូប ព្រោះជាបវេណីធម៌សម្រាប់កាលទាំងពួង ទោះក្នុងពុទ្ធកាលក្តី ក្រៅពុទ្ធកាលក្តី ធម៌នេះគង់នៅថ្មីស្រស់បំព្រងឥតមានចាស់ស្វិតស្រពោនសាបសូន្យទៅទេ ។ ជនដែលបានបំពេញធម៌នេះនឹងត្រូវទទួលលទ្ធផលគឺមានអាយុវែង រមែងជាអ្នកគេចផុតអំពីឧបសគ្គចង្រៃផ្សេងៗបាន ទាំងបច្ចុប្បន្ននិងបរលោក, ខាងចុងបំផុតនឹងបានសម្រេចពុទ្ធញាណ បច្ចេកពោធិញ្ញាណ សាវក-ពោធិញ្ញាណ ចូលកាន់សិវស្ថានគឺព្រះនិព្វាន សមគួរតាមវាសនាបារមីរៀងខ្លួនពុំសោះសូន្យឡើយ ។

អាត្មាភាពពណ៌នាមកក្នុងមតកភត្តទាន នឹងជីវកភត្តទាន សូមបញ្ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។ តែមុននឹងបញ្ចប់នេះ អាត្មាភាពសូមឲ្យតេជានុភាពបុណ្យនៃជីវកភត្តទាននេះ ជួយឧបត្ថម្ភគាំពារឧបាសិ-កាប្រធុម ឲ្យបានជាសះស្បើយពាក់រោគាពាធ ឲ្យមានកម្លាំងមាំមួនចាប់តាំងពីថ្ងៃនេះរៀងទៅ !

ចំណែកអស់លោកអ្នកជាបុត្រធីតាមានលោកឧកញ៉ា យិន-ប៊ឹម ជាដើម ដែលជាអ្នកមានកតញ្ញូបានធ្វើកុសលនេះជូនមាតា សូមឲ្យកុសលនេះជួយឲ្យបានសម្រេចឥដ្ឋមនុញ្ញផលតាមក្តីប្រាថ្នាកុំបីឃ្លៀងឃ្លាត !

— ឯវំ —

# សមភាពក្នុងព្រះពុទ្ធសាសនា

## ឃុនបណ្ឌានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែចាកច្បាប់ធម្មចក្រ អក្សរថៃ

---

សមភាព គឺភាពជាអ្នកស្មើគ្នាក្នុងពួកមនុស្ស ជារឿងដែលគេច្រើនតែនិយាយគ្នាក្នុងផ្លូវលោក ហេតុនេះ គួរនិយាយសមភាពក្នុងផ្លូវធម៌ខាងសាសនាផង ឲ្យឃើញជាគូគ្នា ដើម្បីប្រៀបធៀបមើលដោយហេតុផលថា សមភាពនោះ យើងគួរព្រមទទួលត្រឹមណា ទើបនឹងបានជាការសមរម្យ ។

## សភាពក្នុងលក្ខណៈធម្មតា

មនុស្សយើងដែលកើតមកហើយតែងតែប្រែប្រួលទៅដោយលំដាប់ មិនតាំងនៅដូចដើមទេ គឺតាមដែលមើលឃើញ តាំងពីសម្រាលចាកគភ៌មាតាមកជាកូនខ្ចី ចេះតែចំរើនវ័យឡើងជាក្មេងធំ ជាក្មេងជំទង់ ជាកំលោះក្រមុំ ជាកណ្ដាលមនុស្ស ហើយក៏ចាស់ជរាទ្រុឌទ្រោម ថយចុះដោយលំដាប់ទៅវិញ រហូតដល់ទីបំផុតក៏ស្លាប់ ដូចគ្នាគ្រប់មនុស្សទាំងអស់ ឥតរើសមុខថាអ្នកណាឡើយ ។ នេះជាលក្ខណៈមួយដែលមានស្មើគ្នាទូទៅក្នុងពួកមនុស្សគ្រប់រូប. ក្នុងព្រះពុទ្ធសាសនា ហៅថា អនិច្ចលក្ខណៈ ប្រែថា "លក្ខណៈមិនទៀងទាត់" ។

មួយទៀត គ្រប់មនុស្សដែលកើតមកមានសង្ខាររាងកាយហើយ រមែងមានទុក្ខប្រចាំជាប់មកតែម្ដង ព្រោះសង្ខាររាងកាយនេះនឹងគង់ទ្រង់

រស់នៅបាន  ក៏ត្រូវតែអាស្រ័យបច្ច័យជាគ្រឿងបន្ត  មានអាហារទឹង អាកាសជាដើមជាជំនួយឧបត្ថម្ភជានិច្ច  ហើយមានអាការស្រេកឃ្លានក្នុង វេលាត្រូវការអាហារជាដើម  មនុស្សទើបត្រូវតែថែរក្សាទំនុកបម្រុងឲ្យ សមគួរតាមសេចក្ដីត្រូវការ  ជាការៈដែលត្រូវចាត់ការមិនចេះអស់ហើយ ៗ ប៉ុន្តែកាលបើមនុស្សមិនបានគិតពិចារណាមើល  ប្រិនតែមិនស្រាវដឹងរឿង នេះ  ហើយនៅមានទុក្ខដទៃ ៗ មានសេចក្ដីឈឺចាប់ជាដើមចូលមកបៀត បៀនទៀត  យ៉ាងនេះស្មើគ្នាទាំងអស់ឥតរើសមុខ ៗ នេះជាលក្ខណៈមួយ យ៉ាង  ដែលមានស្មើគ្នាទូទៅក្នុងពួកមនុស្ស,  ក្នុងព្រះពុទ្ធសាសនា ហៅថា  ទុក្ខលក្ខណៈ ប្រែថា  "លក្ខណៈជាទុក្ខ"  ។

មួយទៀត  សេចក្ដីប្រែប្រួលនៃសង្ខាររាងកាយ  និងសេចក្ដីទុក្ខ ផ្សេង ៗ ដែលមានប្រចាំសង្ខារ  សូម្បីជារបស់ដែលមនុស្សមិនត្រូវការ មិនប្រាថ្នា  ប៉ុន្តែមិនអាចនឹងកែខៃឬគេចចៀសវាងឲ្យផុតទៅបាន  គង់តែ ត្រូវកើតមានផ្ទុះតាមសភាពរបស់សង្ខាររាងកាយ  ព្រោះមិននៅក្នុង អំណាចរបស់អ្នកណា ៗ ភាពជារបស់មិននៅក្នុងអំណាច  បង្គាប់បញ្ជា របស់អ្នកណានេះឯង  ជាលក្ខណៈមួយយ៉ាងដែលមានស្មើគ្នាទូទៅក្នុងពួក មនុស្ស.  ក្នុងព្រះពុទ្ធសាសនា  ហៅថា  អនត្តលក្ខណៈ  ប្រែថា "លក្ខណៈមិនមែនជារបស់នៃខ្លួន"  ។

លក្ខណៈទាំង ៣ ប្រការនេះ  មានស្មើគ្នាទូទៅក្នុងពួកមនុស្សទាំង ពួងដែលចាត់ថាជាសង្ខារប្រភេទមួយ  ហៅថា  ឧបាទិន្នកសង្ខារ  ប្រែថា

"សង្ខារមានចិត្តគ្រប់គ្រង" លោកទើបហៅថា សាមញ្ញលក្ខណៈ បាន សេចក្ដីថា មនុស្សគ្រប់រូប មានកើត, ចាស់, ឈឺនឹងស្លាប់ដូចគ្នាទាំងអស់ ទើបឈ្មោះថាជាអ្នកស្មើគ្នា ដោយលក្ខណៈធម្មតា ៣ ប្រការគឺ មិនទៀង, ជាទុក្ខ, ជាអនត្តា មិនប្រព្រឹត្តទៅតាមសេចក្ដីប្រាថ្នា ។ រឿងនេះជាសេចក្ដីពិត ដែលសម្ដេចព្រះបរមសាស្ដាទ្រង់សំដែងដោយហេតុផល; កាលបុគ្គលពិចារណាដោយហេតុផលហើយ រមែងយល់ឃើញតាមការណ៍ពិត គ្មានចន្លោះដែលនឹងទង់ទាញហាមឃាត់បាន ។ នេះឯងជាសមភាព គឺភាពជាអ្នកស្មើគ្នាកងពួកមនុស្សដោយលក្ខណៈធម្មតា ។

## សមភាពក្នុងសេចក្ដីប្រព្រឹត្ដ

ប្រការមួយទៀត សេចក្ដីប្រាថ្នាសុខនឹងមិនប្រាថ្នាទុក្ខ រមែងជាសេចក្ដីចេះដឹងស្មើគ្នាកងពួកមនុស្សទាំងពួង ។ រឿងនេះជាសេចក្ដីពិត អ្នកដែលត្រូវការប្រាថ្នាសេចក្ដីទុក្ខលំបាក សូម្បីតែម្នាក់ក៏គ្មានក្នុងលោក, គ្រប់មនុស្សសុទ្ធតែប្រាថ្នាសុខទាំងអស់គ្នា ប៉ុន្តែមនុស្សទាំងអស់នឹងមានសុខស្មើគ្នាក៏ទេ ព្រោះសុខមិនមែនសម្រេចដល់បុគ្គលដោយគ្រាន់តែមានចិត្តប្រាថ្នាប៉ុណ្ណោះឡើយ ត្រូវតែអាស្រ័យហេតុ គឺការស្វែងរកនឹងការប្រកបធ្វើ ។ អ្នកឈ្លាសវៃដឹងស្គាល់ហេតុនៃសុខហើយធ្វើត្រូវតាមហេតុ រមែងបានសុខដូចប្រាថ្នា ។ ចំណែកអ្នកល្ងង់ខ្លៅ ធ្វើដោយស្មានដោយមិនទាន់បានដឹងហេតុនៃសុខជាមុន តែងប្រទះសុខដោយគាប់

ជួនខ្លះ ឃ្លានទទេទៅខ្លះ ។ ព្រោះហេតុនោះមនុស្សគ្រប់លោកសូម្បី ស្រឡាញ់សុខស្មើគ្នា ប៉ុន្តែបានសុខមិនស្មើគ្នាទេ សូម្បីដូច្នោះ ក៏នៅតែឈ្មោះថា ជាអ្នកស្មើគ្នាដោយសេចក្តីប្រាថ្នាសុខនិងប្រាថ្នាឲ្យផុតទុក្ខ ។ ដោយហេតុនេះ មនុស្សគ្រប់រូបអ្នកត្រូវការសុខ ត្រូវតែបណ្ដុះបណ្ដាលសេចក្តីចេះដឹងហេតុនៃសុខនិងទុក្ខឲ្យកើតមានឡើងក្នុងខ្លួន ដើម្បីចៀសវាងហេតុនៃទុក្ខចេញ ប្រកបហេតុនៃសុខតែម្យ៉ាង ទើបនឹងបានសុខដូចសេចក្តីប្រាថ្នា ។

កាលបើសុខជាទីប្រាថ្នារបស់មនុស្សទូទៅ ឥតសល់ម្នាក់យ៉ាងនេះហើយ វត្ថុណានាំសុខមកឲ្យ វត្ថុណាជាកន្លែងកើតនៃសុខ វត្ថុនោះតែងជាទីប្រាថ្នារបស់មនុស្សទូទៅឥតសល់ម្នាក់ដូចគ្នាដែរ ។ កាលបើមនុស្សគ្រប់រូបនាំគ្នាប្រាថ្នាវត្ថុតែមួយដូចគ្នាយ៉ាងនេះហើយ ក៏ត្រូវតែប្រណាំងប្រជែងដណ្ដើមគ្នាជាធម្មតា ដូចជាការប្រឡងចំណេះវិជ្ជា ដើម្បីដណ្ដើមយកនាទីឋានន្តរសក្តិ ។ កាលបើការដណ្ដើមគ្នាកើតមានឡើងហើយ សេចក្តីទើសទាក់ខ្ទាំងខ្ទប់ទាំងថ្នាក់អាក់អន់ចិត្តក្តៅក្រហាយចិត្តនឹងគ្នាក៏កើតមានឡើង ។ កាលបើការទាំងនេះកើតមានឡើងហើយ សេចក្តីវិវាទឈ្លោះប្រកែកគ្នា សេចក្តីអាឃាតព្យាបាទបំផ្លិចបំផ្លាញគ្នា ក៏រមែងមានឡើង នឹងសេចក្តីបៀតបៀនផ្ដន្ទាឈ្នានីសគ្នាក៏ត្រូវមានតាមគ្នាមកដែរ ព្រមជាមួយនឹងសេចក្តីទុក្ខលំបាក ក្តៅក្រហាយដោយប្រការផ្សេងៗ ។

កាលបើដូច្នេះ ផ្លូវលោកនឹងជាសុខដូចសេចក្ដីប្រាថ្នា ក៏ប្រែក្លាយទៅជាបានទុក្ខលំបាកក្ដៅក្រហាយ ដែលមិនមានអ្នកណាប្រាថ្នាឡើយ ។ រឿងនេះបង្អួលឲ្យឃើញថា មនុស្សជាច្រើនរូបធ្វើខុសច្បាប់នៃសមភាពនឹងខុសសេចក្ដីប្រាថ្នារបស់ខ្លួនឯង ទាំងនេះ ក៏ព្រោះតែសេចក្ដីប្រាថ្នារបស់ខ្លួនឯងនោះហើយជាដើមហេតុ ។

ដើម្បីនឹងការពារផលដែលមិនគួរប្រាថ្នា មិនឲ្យកើតឡើងបាន ដើម្បីនឹងឲ្យមនុស្សផុតចាកសេចក្ដីបៀតបៀនបំផ្លាញគ្នា មនុស្សគ្រប់រូបទើបត្រូវតែមានសមភាពក្នុងសេចក្ដីប្រព្រឹត្តចំពោះគ្នា គឺថាទាំងអស់គ្នាត្រូវតែប្រព្រឹត្តក្នុងផ្លូវដែលនឹងមិនប្រទូសរ៉ាយ ចំពោះសមភាពក្នុងសេចក្ដីប្រាថ្នារបស់គ្នានឹងគ្នាមួយជាន់ទៀត ។ សមភាពក្នុងសេចក្ដីប្រព្រឹត្តនេះ ក្នុងព្រះពុទ្ធសាសនាព្រះបរមសាស្ដាទ្រង់បញ្ញត្តហៅថា ៖

សីលសាមញ្ញតា "ភាពជាអ្នកស្មើគ្នាដោយសីល" ។ សីលប្រែថា ប្រក្រតី សំគាល់សេចក្ដីថា មិនកំរើក. ភាពជាអ្នកស្មើគ្នាដោយសីល សំគាល់សេចក្ដីថា ភាពជាអ្នកមានសេចក្ដីប្រព្រឹត្តផ្លូវកាយវាចារៀបរយស្មើគ្នា បានដល់វៀរចាកការសម្លាប់រហូតដល់ការប្រទូសរ៉ាយក្នុងកាយ ១ វៀរចាកការលួចទ្រព្យសម្បត្តិរហូតដល់ការទំលាយទ្រព្យរបស់អ្នកដទៃ ១ វៀរចាកការគន្លងល្មើសក្នុងភរិយានឹងបុត្ររបស់អ្នកដទៃ ១ វៀរចាកការនិយាយកុហកបំផ្លាញប្រយោជន៍របស់អ្នកដទៃ ១

វៀរចាកការសេពរបស់ស្រវឹងមានសុរាជាដើមដែលធ្វើឲ្យខូចស្មារតីមិនដឹងខុសនឹងត្រូវ ១ រួមជា ៥ ប្រការ ហៅថា បញ្ចវេរវិរតិ ប្រែថា "វៀរចាកពៀរប្រាំ" ព្រោះការប្រព្រឹត្តកម្ម ៥ ប្រការនេះ ជាការកឲ្យកើតពៀរ គឺសេចក្តីអាឃាតព្យាបាទបំផ្លិចបំផ្លាញគ្នាឲ្យកើតមានឡើង ៗ

មែនពិត ជីវិតនិងកាយរមែងជាទីស្រឡាញ់របស់មនុស្សទូទៅ រហូតដល់សត្វមានជីវិតទាំងពួង កាលបើមានគេប្រទូសរ៉ាយ ក៏រមែងឈឺចាប់លំបាក ហើយចងអាឃាតព្យាបាទតបទៅវិញខ្លះ ទាំងអ្នកធ្វើទាំងអ្នករងអំពើក៏គ្មានប្រក្រតីសុខទាំងអស់គ្នា រេះតែមានពៀរមានភ័យជានិច្ច ព្រោះគំនិតប្រុងប្រទូសរ៉ាយបំផ្លិចបំផ្លាញគ្នា ៗ ទ្រព្យសម្បត្តិរបស់អ្នកណា អ្នកនោះតែងតែស្រឡាញ់ប្រកាន់ស្តាយ កាលបើមានចោរលួចឆក់ដណ្តើមឬក៏បាត់បង់ខូចខាតទៅ ក៏តែងតូចចិត្តកើតទុក្ខសោកស្តាយ កើតគំនិតគុំគួនចងអាឃាតដល់អ្នកធ្វើ ៗ បុត្រភរិយារមែងជាទីស្រឡាញ់ ជាទីជាប់ចិត្តអាឡោះអាល័យ កាលបើមានការគន្លងល្មើសកើតឡើង ធ្វើសេស្រឡាយ នៃវង្សត្រកូលឲ្យប្រឡូកប្រឡំសៅហ្មងមិនស្អាតបរិសុទ្ធ ជាទីមើលងាយ ៗ មនុស្សយើងក្រៅពីការស្រឡាញ់បុត្រភរិយាហើយ រមែងមានសេចក្តីស្រឡាញ់វង្សត្រកូលយ៉ាងក្រៃលែង ព្យាយាមនឹងគ្រប់គ្រងថែរក្សាឲ្យបរិសុទ្ធផូរផង់តាមសេចក្តីនិយមរបស់លោក កាលបើមានគេហ៊ានប្រមាថមើលងាយប្រព្រឹត្តគន្លងប្រពៃណីហើយ ក៏កើតសេចក្តី

ក្តៅក្រហាយឈឺចាប់ចង់គំនុំគាឃាតព្យាបាទ ៗ មនុស្សក្នុងលោក កាលបើថាដោយគោលធម៌ហើយ សុទ្ធតែត្រូវការសេចក្តីស្មោះត្រង់ដល់គ្នាទាំងអស់ សូម្បីពាក្យសំដីដែលនិយាយគ្នា ក៏ប្រាថ្នាឲ្យបានឮបានស្តាប់តែពាក្យដែលពិតប្រាកដ មិនកុហកបញ្ឆោត ព្រោះពាក្យពិតមិនធ្វើឲ្យខូចប្រយោជន៍ មានតែឲ្យសម្រេចប្រយោជន៍ នឹងធ្វើឲ្យជាទីជឿទុកចិត្តដល់គ្នាទៅវិញទៅមក សឹងជាផ្លូវផុតភ័យយ៉ាងឯក ៗ លោកនេះ បើមានតែសេចក្តីពិតដល់គ្នានឹងគ្នាហើយ នឹងស្ងប់ជាប្រក្រតី សុខគ្មានអ្វីប្រៀបផ្ទឹមបាន ប៉ុន្តែប្រព្រឹត្តទៅមិនកើត ព្រោះមនុស្សក្នុងលោកមានកិលេសហើយឃើញតែខ្លួនឯងមួយ ៗ សូម្បីអ្នកណាក៏ដោយ កាលបើមានគេនិយាយកុហកបញ្ឆោតហើយ ក៏រមែងចូលចិត្តខុសហើយដំណើរការខុសទៅតាម ខូចខាតប្រយោជន៍ដែលខ្លួននឹងត្រូវបានត្រូវសម្រេច ៗ ព្រោះហេតុនោះ បានជាគ្មានអ្នកណាចូលចិត្តស្រឡាញ់ពាក្យកុហកសោះ សូម្បីខ្លួនអ្នកដែលច្រើនតែនិយាយកុហកគេ ក៏មិនចូលចិត្តឲ្យអ្នកណាមកនិយាយកុហកខ្លួនវិញដែរ ចូលចិត្តឲ្យគេនិយាយតែពាក្យពិត កាលបើមានគេនិយាយកុហកក៏កើតក្រោធខឹងស្អប់ខ្ពើមលែងជឿទុកចិត្តគេតទៅមុខទៀត ខ្លួនអ្នកដែលមិនចូលចិត្តពាក្យកុហកសោះ ក៏បេះតែនៅនិយាយកុហកគេជាដរាប ជាអ្នកប្រទូសរ៉ាយដល់គោលធម៌ក្នុងខ្លួនឯង នឹងជាអ្នកប្រទូសរ៉ាយដល់គោលធម៌របស់លោក ឈ្មោះថា

ទំលាយប្រយោជន៍ខ្លួនឯងនិងអ្នកដទៃទាំងពីរខាង ព្រោះសេចក្ដីឃ្លៀងឃ្លាតលែងទុកចិត្តគ្នាកើតមកតែអំពីមនុស្សវៀច ច្រើនតែនិយាយកុហកជាត្រីមុខ ៗ ការធ្វើ ការនិយាយ, ការគិត ដែលទឹងប្រព្រឹត្តទៅក្នុងផ្លូវត្រូវ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃនោះ រមែងកើតមានដល់អ្នកមានសតិដុំរិញ ៗ ធម្មតាសាមញ្ញជន សូម្បីកាលនៅមិនទាន់ស្រវឹងក៏គង់តែមានវេលាភ្លេចភ្លាំង ធ្វើខុស និយាយខុស គិតខុស បង្កសេចក្ដីវិនាសដល់ខ្លួននិងអ្នកដទៃ កាលបើចេះតែសេពរបស់ស្រវឹងធ្វើឲ្យខូចសតិថែមលើសដើមឡើងទៀត សេចក្ដីខុសខូចកោងកាចអាក្រក់រឹងរឹតតែមានកម្លាំងខ្លាំងឡើងទាល់តែផុតថា នឹងនិយាយក៏មិនអស់មិនចប់ មានតំរូវនៅគរគោក និយាយយ៉ាងងាយៗ ត្រង់ការបង្កសេចក្ដីរំខានចិត្តដល់អ្នកនៅជិតខាងដូចជាក្នុងក្រុមគ្រួសាររបស់ខ្លួន លោកថាអ្នកស្រវឹងស្រាហើយ តែងបង្កពៀរ ៥ ប្រការខាងដើមបានដោយងាយណាស់ ព្រោះហេតុនោះការផឹកទឹកស្រវឹង ទើបចាត់ថាជាហេតុកពៀរភ័យ ៗ ចំណែកបញ្ចវេរវិរតិ គឺការលះវៀរចាកពៀរ ៥ ជាគុណធម៌កំចាត់ភ័យពៀរក្នុងលោក ទើបចាត់ថាជាសីល ព្រោះធ្វើលោកឲ្យជាប្រក្រតីសុខប្រាសចាកការបៀតបៀនបំផ្លាញគ្នានឹងគ្នា ៗ កាលមនុស្សទាំងពួងតាំងចិត្តរក្សាសីល ៥ ប្រការនេះជានិច្ច មិនហ៊ានឈានកន្លងព្រោះហេតុអ្វីៗហើយ មនុស្សគ្រប់រូបក៏ឈ្មោះថាមានសមភាពក្នុងសេចក្ដីប្រព្រឹត្ត

សមជាមនុស្សដែលរាប់ថាមានអារ្យធម៌ ។ ការដែលមនុស្សគ្រប់រូបជាអ្នកមានសីលស្មើគ្នានេះឯង ហៅថា សីលសាមញ្ញតា ភាពជាអ្នកស្មើគ្នាដោយសីល ។

អ្នកណាប្រព្រឹត្តបែកផ្សេងខុសនឹងបក្សពួករបស់ខ្លួន ដោយត្រឡប់យល់ឃើញរបស់ដែលគេនិយមថាអាក្រក់វិនាស ក្លាយជារបស់ល្អ អ្នកនោះរមែងជាទីស្អប់ខ្ពើមជាទីរង្កៀស របស់ពួកដែលបែកចាកពួកទៅ ដែលហៅថា បែកសាមគ្គី រមែងឲ្យផលអាក្រក់ដល់ខ្លួនឯង នឹងប្រទាញកំឡាំងរបស់ពួកឲ្យថយចុះ ព្រោះហេតុនោះ សីលសាមញ្ញតា ទើបចាត់ជាធម៌ជាទីតាំងនៃសាមគ្គីផង ។

## សមភាពក្នុងសេចក្ដីយល់ឃើញ

មនុស្សត្រូវតែនៅរួបរួមគ្នាជាពួកទើបបាន ត្រូវពឹងពាក់អាស្រ័យគ្នា ត្រូវរួមកម្លាំងជួយគ្នារក្សាពួករបស់ខ្លួនឯង សូម្បីមានសេចក្ដីស្មើគ្នាដោយការប្រព្រឹត្តល្អ ជាគ្រឿងការពារសេចក្ដីបៀតបៀនបំផ្លាញគ្នាហើយក្ដី ប៉ុន្តែបើមានសេចក្ដីយល់ឃើញមិនស្មើគ្នាទេ រមែងជាហេតុឲ្យបែកសាមគ្គី វិវាទទាស់ទែងគ្នា បន្ថយកម្លាំងគ្នាឯង នាំសេចក្ដីវិនាសមកឲ្យដល់ពួកគណៈរបស់ខ្លួនឯង ។ ព្រោះហេតុនោះ មនុស្សអ្នករួមគ្នាជាពួកគណៈ ត្រូវតែមានសមភាពក្នុងសេចក្ដីយល់ឃើញខ្វះមិនបានទេ ដើម្បីជាគ្រឿងការពារសេចក្ដីបែកសាមគ្គី ។ សមភាពក្នុងសេចក្ដីយល់ឃើញនេះ ជាពាក្យក្នុងព្រះពុទ្ធសាសនា ព្រះបរមសាស្ដាទ្រង់បញ្ញត្តហៅថា ៖

ទិដ្ឋិសាមញ្ញតា "ភាពជាអ្នកស្មើគ្នាដោយសេចក្ដីយល់ឃើញ" ។

សេចក្ដីយល់ឃើញនេះ ភាសាបាលីហៅថា ទិដ្ឋិ ជាពាក្យកណ្ដាលៗ, បើសំគាល់សេចក្ដីខាងល្អ ថែម សម្មា នៅខាងដើមជា សម្មាទិដ្ឋិ (សេចក្ដីយល់ឃើញត្រូវ), បើសំគាល់សេចក្ដីខាងអាក្រក់ ថែម មិច្ឆា ភ្ជាប់ខាងដើមជា មិច្ឆាទិដ្ឋិ (សេចក្ដីយល់ឃើញខុស), បើចំពោះតែកម្លាំងសព្ទថា ទិដ្ឋិ គ្មានសព្ទដទៃនៅខាងដើមឬខាងចុងទេ សំគាល់សេចក្ដីទាំងខាងល្អទាំងខាងអាក្រក់ តែក្នុងទីនេះ សំគាល់សេចក្ដីតែខាងល្អ ។ ទិដ្ឋិ (សេចក្ដីយល់ឃើញ) នេះជារបស់សំខាន់ណាស់, បើមានសេចក្ដីយល់ឃើញខុស ក៏ជាហេតុឲ្យធ្វើខុស និយាយខុស គិតខុស នាំទោសទុក្ខភ័យអន្តរាយនិងសេចក្ដីវិនាសមកឲ្យខ្លួនឯងនិងពួកគណៈរបស់ខ្លួន, បើមានសេចក្ដីយល់ឃើញត្រូវ ក៏ជាហេតុឲ្យធ្វើត្រូវ និយាយត្រូវ គិតត្រូវ នាំគុណប្រយោជន៍ សុខសួស្ដីមកឲ្យខ្លួននិងពួកគណៈរបស់ខ្លួន ។ ព្រោះហេតុនោះសេចក្ដីយល់ឃើញទើបជារបស់ដែលគួរតែប្រុងប្រយ័ត្ន ឲ្យប្រព្រឹត្តទៅតែក្នុងផ្លូវដែលត្រូវ ។ សេចក្ដីយល់ឃើញឯណា មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃ សេចក្ដីយល់ឃើញនោះជាសេចក្ដីយល់ឃើញត្រូវ ដូចសេចក្ដីដែលយល់ឃើញថា របស់ទាំងពួងរមែងជាប់ដោយហេតុផល ហើយ

ផលរមែងប្រព្រឹត្តទៅតាមអំណាចនៃហេតុ មានដើមថា មនុស្សដែលកើតមករួមពួកគណៈគ្នានេះ សូម្បីជាអ្នកមានសេចក្តីកើត ចាស់ ឈឺ ស្លាប់ជាធម្មតាស្មើគ្នា ទាំង សូម្បីជាអ្នកស្រឡាញ់សុខស្អប់ទុក្ខស្មើគ្នាក៏ពិតមែនហើយ ប៉ុន្តែសូម្បីដូច្នោះ ក៏នៅតែជាអ្នកមិនស្មើគ្នាដោយហេតុគឺកម្មរបស់ខ្លួនឯងដែលបានធ្វើទុកមក អំណោយចំណែកឲ្យជាអ្នកល្អខ្លះ អាក្រក់ខ្លះ ផ្សេងៗ គ្នា គឺមនុស្សខ្លះមានអាយុវែង មនុស្សខ្លះមានអាយុខ្លី មនុស្សខ្លះមានរោគភ័យបៀតបៀនមិនសមប្រកប មនុស្សខ្លះសមប្រកបគ្មានរោគភ័យបៀតបៀន មនុស្សខ្លះទាល់ក្រអនាថា មនុស្សខ្លះមានធនធានយ៉ាងសម្បូណ៌ មនុស្សខ្លះជាទីស្អប់ខ្ពើម មានសឹកសត្រូវច្រើន មនុស្សខ្លះជាទីស្រឡាញ់ពេញចិត្តអាណិតអាសូររបស់ជនទាំងឡាយ គ្មានសឹកសត្រូវ មនុស្សខ្លះជាទីជឿស្តាប់របស់ជនទាំងឡាយ មនុស្សខ្លះជាទីប្រមាថមើលងាយ មិនជាទីជឿស្តាប់របស់អ្នកណា មនុស្សខ្លះរេងរេវិកលចរិត មនុស្សខ្លះសម្បូណ៌ដោយសេចក្តីគិតសេចក្តីចេះដឹង មនុស្សខ្លះល្ងង់ខ្លៅ មនុស្សខ្លះមានប្រាជ្ញាឈ្លាសវៃ មនុស្សខ្លះមានតេជានុភាពជាទីកប់អានកោតក្រែង មនុស្សខ្លះគ្មានតេជានុភាព មិនជាទីគោរពកោតក្រែងប៉ុណ្ណោះជាដើមជាគ្រឿងចង្អុលឲ្យឃើញថា ជាផលដែលជាប់មកអំពីហេតុ ប្រព្រឹត្តទៅតាមហេតុ ។ បើយើងជឿហេតុផល ទាំងមានសេចក្តីយល់ឃើញកង់គន្លងនៃហេតុផលហើយ ក៏ទាំងសន្និដ្ឋានបាន

ថា ចំណែកដែលល្អដូចភាពជាអ្នកមានអាយុវែងជាដើម រមែងជាផលនៃហេតុគឺកម្មខាងល្អពិតប្រាកដ, ចំណែកដែលអាក្រក់ ដូចភាពជាអ្នកមានអាយុខ្លីជាដើម រមែងជាផលនៃហេតុគឺកម្មខាងអាក្រក់ពិតប្រាកដ, កាលខ្លួនធ្លាក់នៅក្នុងឋានៈដូចម្ដេច ក៏នឹងធ្វើខ្លួនឲ្យជាអ្នកសមគួរដល់ឋានៈដូច្នោះ គឺថាកាលធ្លាក់នៅក្នុងចំណែកអាក្រក់ថោកទាបជាងគេ ក៏មិនតូចចិត្តស្ដាយឈ្នានីសអ្នកដទៃដែលមានឋានៈល្អជាងខ្លួន រមែងជាអ្នកដឹងខ្លួនបានថាព្រោះយើងធ្វើកម្មមិនល្អ ដែលនឹងអំណោយផលដូច្នេះទុកមក បានជាត្រូវយ៉ាងនេះ ហើយព្យាយាមប្រឹងប្រែងយត្នខ្លួនមិនធ្វើកម្មអាក្រក់ ធ្វើតែកម្មដែលល្អជាគ្រឿងកែខៃ ក៏នឹងបានជាអ្នកមានឋានៈល្អឡើងដោយលំដាប់, បើជាអ្នកធ្លាក់នៅក្នុងចំណែកល្អខ្ពង់ខ្ពស់ជាងគេ ក៏មិនគប្បីប្រកាន់ខ្លួនប្រណាំប្រមាថមើលងាយអ្នកដទៃ ដែលមានឋានៈថយថោកជាងខ្លួន នឹងមិនគប្បីប្រណែនឫស្យាអ្នកដទៃ ដែលមានឋានៈស្មើនឹងខ្លួន ព្រោះបានពិចារណាឃើញថា ដែលយើងជាអ្នកមានឋានៈល្អប្រសើរជាងគេ ឬស្មើមុខនឹងគេដូច្នេះ ក៏ព្រោះតែយើងបានធ្វើកម្មល្អ ដែលនឹងឲ្យផលល្អទុកមក កម្មល្អទើបអំណោយឲ្យយើងបានត្រឹមនេះ នឹងខំព្យាយាមធ្វើកម្មល្អឲ្យរឹតតែច្រើនៗ ឡើងទៅទៀត ក៏នឹងបានជាអ្នកល្អរឹតតែច្រើនឡើងដរាបទៅ មិនធ្លាក់ថោកទាប ។ សេចក្ដីយល់ឃើញដែលនៅក្នុងគន្លងហេតុផលដូច្នេះ រមែងជាហេតុការពារមិនឲ្យបុគ្គលធ្លាក់ទៅ

ក្នុងផ្លូវថោកទាប មានតែត្រឡប់ផ្ដើមឲ្យជាអ្នកល្អច្រើនឡើង ទាំងជាគ្រឿងហាមឃាត់សេចក្ដីឫស្យាគ្នា សេចក្ដីប្រកាន់ខ្លួនប្រណាមើលងាយអ្នកដទៃ និងសេចក្ដីសង្កត់សង្កិនគ្នាមិនឲ្យកើតឡើងបាន ។ កាលមនុស្សអ្នករាប់ជាប់ក្នុងពួកជាមួយគ្នា ជាអ្នកមានសេចក្ដីយល់ឃើញត្រូវស្មើគ្នា ពួកគណៈក៏រមែងមានសេចក្ដីចំរើនដោយបុគ្គលអ្នកល្អ នៅរួមគ្នាជាពួកដោយសេចក្ដីស្រុះស្រួល មានសេចក្ដីសុខទូទៅគ្រប់គ្នា ។

ប្រការមួយទៀត ជនទាំងឡាយនៅជាពួក និងរួបរួមគ្នាជាពួកបានត្រូវតែអាស្រ័យសេចក្ដីព្រមព្រៀងជួយគ្នាធ្វើមុខការ គឺត្រូវគោរពដល់មុខការរបស់ខ្លួន ដោយអើពើយកចិត្តទុកដាក់ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ និងត្រូវគោរពដល់មុខការរបស់អ្នកដទៃ ដោយមិនប្រតិបត្តិការឲ្យជាទីទើសទាស់ដល់មុខការរបស់អ្នកដទៃ ដោយមិនមើលងាយ ហើយត្រូវព្រមទទួលសម្មតិដែលជាប់ដោយខ្លួន ។ បុគ្គលអ្នកធ្វើមុខការ ដូចព្រមទទួលថាអ្នកនោះអ្នកនេះជាធំ ជាប្រធានអ្នកដឹកនាំឬជាអ្នកគ្រប់គ្រងរបស់ពួក បុគ្គលនោះតែងនៅក្រោមបង្គាប់បញ្ជា ហើយប្រតិបត្តិតាមមុខការរបស់ខ្លួនតាមដែលកើតមានដូចម្ដេច មិនប្រកាន់ថាស្មើគ្នាដូចគ្នាទាំងអស់ដ៏ជាការបដិសេធសម្មតិដែលមិនមានអ្នកណាអាចបដិសេធបាន ។ ព្រោះលោកគឺប្រជុំជននៅរួមគ្នាបាន ក៏ដោយអាស្រ័យសម្មតិ ហើយប្រតិបត្តិដំណើរការជាប់ទាក់ទងគ្នាក្នុងវិថីនៃសម្មតិ មិនឲ្យខុសចាកសម្មតិទៅបាន

ដូចសម្មតិថាមាតាបិតា បុត្រធីតា ស្វាមីភរិយា ញាតិមិត្រជាដើម ទាំងនេះជាប់ដោយមុខការប្រចាំខ្លួនដែលនឹងត្រូវប្រតិបត្តិដល់គ្នាជាសំខាន់ បើនឹងលះវៀរមុខការប្រចាំខ្លួនរបស់ជនទាំងនេះចេញ លោកក៏តាំងនៅមិនបាន សម្មតិក៏អស់នាទី ៗ មួយទៀត បើលោកនេះនឹងមិនមានសម្មតិហើយ មនុស្សនឹងធ្វើសេចក្តីចូលចិត្តរាប់អានគ្នាមិនបានឡើយ ព្រោះហេតុនោះ សម្មតិទើបជារបស់ដែលលើកចោលមិនបាន សូម្បីពួកជននឹងប្រើការគ្រប់គ្រងគ្នាដោយវិធីណាក៏ដោយ ៗ ដោយហេតុនេះ អ្នកមានសេចក្តីយល់ឃើញត្រូវ រមែងយល់ឃើញថា ការដែលសម្មតិថាអ្នកនោះជាធំជាប្រធានជាអ្នកដឹកនាំឬជាអ្នកគ្រប់គ្រង ឬថាអ្នកនោះជាអ្នកបង្គាប់បញ្ជា អ្នកនោះជារងបន្ទាប់ជាអ្នកនៅក្រោមបង្គាប់បញ្ជាជាដើមនេះ មិនមែនជាការទំលាយរំលាងសមភាពក្នុងពួកជនទេ ត្រឡប់ជាការរក្សាសមភាពក្នុងពួកជនឲ្យមាំមួនទៅវិញ ៗ ព្រោះពួកនឹងតាំងនៅបានក៏ដោយអ្នកមានមុខការស្រុះស្រួលជួយគ្នាធ្វើការតាមនាទី ដោយអើពើស្មើគ្នា ៗ កាលអ្នកណាបានទទួលសម្មតិឲ្យធ្វើនាទីរបស់អ្នកដឹកនាំពួក បើជនអ្នកនៅរួមពួកដ៏រាប់ថាជារងបន្ទាប់ មានសេចក្តីគោរពចំពោះនាទីរបស់អ្នកនោះ ប្រតិបត្តិការតាមនាទីរបស់អ្នករងបន្ទាប់ដោយត្រឹមត្រូវ នាទីអ្នកដឹកនាំដែលសម្មតិតែងតាំងគ្នាឡើងនោះ ក៏រមែងសំរេចប្រយោជន៍ កិច្ចការរបស់ពួករមែងដំណើរទៅដោយរៀបរយ ៗ

បើជនអ្នកនៅរួមពួកជាមួយគ្នា  មិនគោរពចំពោះនាទី  របស់អ្នកដឹកនាំ ហើយ  បេះតែបែកខ្ញែកពីគ្នាធ្វើតែតាមអំពើចិត្តរៀងខ្លួនទៅហើយ  កិច្ចការទាំងឡាយក៏ខ្ចាត់ខ្ចាយផ្តេសផ្តាស  ល្អខ្លះអាក្រក់ខ្លះ  ប្រឡូកប្រឡំគ្នាអស់ឥតរបៀប  ជាការបន្ថយសមភាព  ទាំងបន្ថយកម្លាំងសេចក្តីចំរើនរបស់ពួកឲ្យអន់ថយចុះទៅ  រហូតដល់តាំងនៅមិនបាន ។ ព្រោះហេតុនោះ  គ្រប់ពួកមិនរើសថាតូចឬធំទេ  ដូចគ្រួសារមួយ  ឬភូមិប្រទេសមួយ  ទើបត្រូវតែមានប្រធានអ្នកដឹកនាំខ្វះមិនបាន ។ សូម្បីក្នុងខ្លួនឯងអវយវៈទាំងឡាយរមែងធ្វើមុខការទាំងអស់គ្នា  ភ្នែកជាអ្នកដឹកនាំ  ទើបបាននាមថានេត្រ  ខួរក្បាលមាននាទីគិតអានត្រិះរិះរួមនៅត្រង់ក្បាល យើងទើបលើកក្បាលថាខ្ពស់  តែការសំខាន់របស់អវយវៈនោះ  ក៏គឺជួយគ្នា  ធ្វើនាទីឲ្យរាងកាយនេះប្រព្រឹត្តទៅដោយល្អ  ដោយមិនបេះរង្កៀសប្រណែនប្រចាំគ្នាឡើយ  រាងកាយនេះទើបគង់នៅបាន ។ រាងកាយរបៀបដូចពួក  ភ្នែកឬខួរក្បាលប្រៀបដូចប្រធានអ្នកដឹកនាំរបស់ពួក  ពួកជនរមែងខ្ពស់ទាបជាងគ្នាដោយដំណែងនាទី  រហូតដល់គុណធម៌សេចក្តីឈ្លាសវៃនិងអាច  តែរមែងស្មើគ្នាដោយសេចក្តីត្រូវធម៌ដែលគ្រប់មនុស្សមាន  និងប្រយោជន៍ដែលនឹងគប្បីបានរួមគ្នាក្នុងការងាររបស់ពួក ។ កាលសេចក្តីស្មើគ្នាមានឡើងដោយហេតុផល  សូម្បីសេចក្តីខ្ពស់ទាបជាងគ្នា  ក៏រមែងមានឡើងដោយហេតុផលដូចគ្នា,  ការ

ដែលនឹងយកគំនិតឲ្យស្មើគ្នាទៅទាំងអស់គ្រប់របស់គ្រប់យ៉ាងនោះ រមែងប្រព្រឹត្តទៅមិនបានឡើយ ព្រោះទើសទាក់ដល់គោលធម៌គឺហេតុផល សម្បីព្រះអរិយបុគ្គលក្នុងព្រះពុទ្ធសាសនា គង់តែនៅមានខ្ពស់ទាបជាង ៗ គ្នាដោយជាន់នៃមគ្គផល តែស្មើគ្នាតាមគោលនៃសមភាពដូចពោលមកហើយ ។ សេចក្តីយល់ឃើញត្រូវតាមគោលនៃសមភាព ដ៏ប្រកបដោយហេតុផលនេះ រមែងជាគុណគួរប្រាថ្នាក្នុងពួកជនអ្នកនៅជាពួកគណៈ ដើម្បីកំចាត់ការបែកសាមគ្គី និងការប្រណាំងប្រជែងសង្កត់សង្កិនគ្នាឯង ព្រោះហេតុនោះ ទិដ្ឋិសាមញ្ញតា "ភាពជាអ្នកស្មើគ្នាដោយសេចក្តីយល់ឃើញ" ទើបជាធម៌ដែលគួរប្រាថ្នាយ៉ាងក្រៃលែង ។

ភាពជាអ្នកស្មើគ្នាដោយសេចក្តីយល់ឃើញក្នុងទីនេះ ដោយន័យដ៏ទៀងទាត់ សំដៅយកសេចក្តីយល់ឃើញរួមគ្នា ក្នុងផ្លូវដែលត្រូវតាមគន្លងធម៌ ។ ធម្មតាបុគ្គលរមែងមានសេចក្តីយល់ឃើញបែកផ្សេងគ្នាទៅបាន តាមសេចក្តីគិតឃើញរបស់ខ្លួន ប៉ុន្តែបើក្នុងរបស់ដូចគ្នា កើតមានសេចក្តីយល់ឃើញបែកផ្សេងគ្នាឡើង រមែងប្រព្រឹត្តទៅដើម្បីវិវាទឈ្លោះប្រកែកគ្នា ។ កាលចំណែកម្ខាងប្រកាន់ថារបស់ខ្លួនត្រូវ ក៏គ្មានផ្លូវដែលនឹងស្រុះស្រួលគ្នាបាន ។ ព្រោះហេតុនោះ សេចក្តីយល់ឃើញត្រូវតែមានគន្លងធម៌ជាគោល, សេចក្តីយល់ឃើញរបស់ចំណែកខាងណាមិនប្រកបដោយគន្លងធម៌ ចំណែកខាងនោះរមែងប្រកាន់មិនបាន

មិនគួរប្រកាន់អាងសេចក្ដីយល់ឃើញរបស់ខ្លួនទុកទេ គួរតែព្រមតាមចំណែកដែលប្រកបដោយគន្លងធម៌ ។ គន្លងធម៌ក្នុងទីនេះ បានដល់ផ្លូវដែលមិនខូចផល ទាំងរបស់ខ្លួន ទាំងរបស់ជនទូទៅ ។ មួយទៀត សូម្បីនឹងមានសេចក្ដីយល់ឃើញរួមគ្នាទាំងអស់ក្នុងពួកជាមួយគ្នា ប៉ុន្តែបើមិនប្រព្រឹត្តទៅតាមគន្លងធម៌ទេ ក៏មិនបានជាការ ព្រោះប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាសដល់មនុស្សទាំងពួង ទាំងទំនាស់នឹងសេចក្ដីយល់ឃើញរបស់ជនពួកដទៃដែលប្រកបដោយគន្លងធម៌ ជាផ្លូវឲ្យបែកសាមគ្គីនឹងពួកដទៃតទៅទៀត ។ ព្រោះហេតុនោះ គួរតែមានសេចក្ដីយល់ឃើញរួមគ្នាចំពោះតែក្នុងគន្លងធម៌ប៉ុណ្ណោះ ទើបនឹងអាចរក្សាសាមគ្គីទុកបានដោយទូទៅ ។

ព្រះបរមសាស្ដាទ្រង់សំដែងសមភាព គឺភាពជាអ្នកស្មើគ្នាក្នុងពួកមនុស្ស ដោយគោលធម៌ ៣ ប្រការ គឺទ្រង់សំដែងសមភាព ដោយន័យនៃសាមញ្ញលក្ខណៈថា គ្រប់មនុស្សធ្លាក់នៅក្នុងលក្ខណៈដែលមិនទៀង ជាទុក្ខ ជាអនត្តា ការដែលបានឃើញ គឺកើតមកហើយក៏ចាស់ ឈឺ ស្លាប់ដូចគ្នាទាំងអស់ ដូច្នេះ ដើម្បីឲ្យឃើញសេចក្ដីវិនាសសាបសូន្យ សេចក្ដីមិនស្ថិតស្ថេរ នឹងបានជាអ្នកមិនប្រមាទស្រវឹង ក្នុងវ័យ ក្នុងសេចក្ដីមិនមានរោគ ក្នុងជីវិត ក្នុងរបស់សំឡាញ់ ។ ទ្រង់សំដែងភាពជាអ្នកស្មើគ្នា ដោយសេចក្ដីប្រព្រឹត្តល្អ ដែលហៅថា

សីលសាមញ្ញតា ដើម្បីហាមឃាត់សេចក្ដីបៀតបៀនបំផ្លាញគ្នា ។ ទ្រង់សំដែងភាពជាអ្នកស្មើគ្នា ដោយសេចក្ដីយល់ឃើញត្រូវតាមគន្លងធម៌ ដែលហៅថា ទិដ្ឋិសាមញ្ញតា ដើម្បីហាមឃាត់សេចក្ដីយល់ឃើញខុសផ្លូវ នឹងសេចក្ដីវិវាទទាស់ទែងបែកសាមគ្គី ។ សមភាព ៣ ប្រការនេះ ជាគោលធម៌សំខាន់នៃកន្លែងរបស់លោក ជារបស់ទៀងទាត់មិនប្រែប្រួល ព្រោះហេតុណា ។ បើជនក្នុងលោកទាំងមូលព្រមគ្នាប្រតិបត្តិតាមគោលសមភាព ៣ ប្រការនេះគ្រប់គ្នាហើយ លោកនឹងដល់សន្តិសុខ ប្រាសចាកភ័យពៀរនឹងសេចក្ដីចង្អៀតចង្អល់ ទើសទាក់ដោយប្រការទាំងពួង ព្រោះមនុស្សនឹងធ្វើសេចក្ដីល្អដល់គ្នា គឺជួយទំនុកបំរុងគ្នា នាំគ្នាទៅកាន់សេចក្ដីសួស្ដីគឺសេចក្ដីផុតភ័យ មិនមានទីបំផុត ព្រោះហេតុនោះអ្នកប្រាថ្នាសន្តិសុខដល់ខ្លួន នឹងដល់ពួកគណៈរបស់ខ្លួន ទើបគួរតែយកចិត្តទុកដាក់ក្នុងសមភាព ៣ ប្រការនេះ ហើយប្រតិបត្តិដំណើរការកុំឲ្យខុសវិថីនៃសមភាពនោះ ។

សូមសេចក្ដីសុខសួស្ដីបវរមានដល់អស់លោកអ្នក

ដោយតេជានុភាពព្រះរតនត្រៃ !

---

## បញ្ញាសជាតក

### ភាគទី ២

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ បាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង
កាលដែលនៅជាភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

---

## សុកមិត្តជាតក ទី ៩

(តមក)

(និយាយអំពីដំណើរព្រាត់ប្រាស ព្រោះមានពៀរដោយយកកូនសត្វ)

លោកអាចារ្យ ឈឹម-ស៊ុម ក្រុមជំនុំព្រះត្រៃបិដក

ប្រែពីបាលី

គ្រានោះ ព្រះបាទក្រុងសុកមិត្តមហារាជ ជាស្តេចចំរើនក្នុងដែនរបស់ជន ទ្រង់មានព្រះរាជឧត្តារថា: កូនតូចៗ របស់យើង ធ្លាប់តែបរិភោគបាយស្រូវសាលី នឹងម្ហូបចំណីមានឱជារសឆ្ងាញ់ពិសា ចុះដល់ចេញទៅនៅក្នុងព្រៃព្រឹក្សា ត្រូវបរិភោគតែផ្លែឈើ តើនឹងធ្វើយ៉ាងម៉េច? ម្យ៉ាងទៀត ធ្លាប់បរិភោគភោជនាហារលើតុកមាសដ៏ថ្លៃថ្លា មានទម្ងន់ ១ រយបល: ជាព្រះរាជទ្រព្យមានជាប់មក ១ រយរាជ្យហើយ, ដល់គ្រាដែលចេញទៅនៅព្រៃ បរិភោគអាហារចំណីលើ

ស៊ីកឈើ តើក្រែងធ្វើដូចេ្នះ មិនកើតទេដឹង? មួយទៀត កុមារទាំងឡាយ កាលនៅទីអាយ ធ្លាប់ស្លៀកដណ្តប់ សុទ្ធសឹងសំពត់កាសិកព័ស្ត ខោមកព័ស្ត ទុម្ពរព័ស្ត មានសាច់ល្អិតម៉ដ្ឋទន់ល្វន់ល្វៃ ដល់ទៅនៅក្នុងព្រៃ ត្រូវស្លៀកដណ្តប់កម្រងស្បូវ តើក្រែងស្លៀកដណ្តប់មិនកើតទេដឹង? មួយទៀត ធ្លាប់ទៅណាមកពីណា សុទ្ធតែទៅមកដោយព្រះសន្លៀងសុពណ៌សិវិកា ឬរាជរថដ៏ថ្លៃថ្លា មានស្នំស្រីគ្នាហែហមត្រៀបត្រា, ដល់វេលាចេញទៅនៅព្រៃព្រឹក្សា ត្រូវតែដើរផ្ទាល់បាទា តើពុំងានាំងឲ្យក្មេងទាំងនេះធ្វើដូចេ្នះដូចម្តេចកើត? មួយទៀត កាលដែលនៅទីឋានអាយ កុមារទាំងឡាយ ធ្លាប់តែផ្ទុំលើទីសយនាក្រឡាបទុំ ដែលក្រាលដោយរៀបចំព្រែព្រៃ ពូកខ្នើយរងព្រះសិរ រងព្រះបាទា បិទបាំងដោយព្រះសន្ទិយា នៅនាប្រាង្គប្រាសាទ ដ៏ល្អស្អាតមានទ្វារបង្អួចគន្លឹះ បង់បើកឬបិទក៏បានតាមប្រាថ្នា ជាទីដ៏ថ្លៃថ្លាក្តីផ្ទុកបិញ្ញាចបិញ្ចួន, ដល់វេលាដែលនិរាសចាកកន្លែងស្នេងទៅនៅព្រៃ ក្រែងបុត្រពីសីផ្ទុំលើកម្រាលស្បូវក្រាលផ្ទាប់នឹងគល់ឈើមិនកើតទេដឹង? មួយទៀត; កុមារទាំងឡាយ ធ្លាប់តែលាបស្រឡាបកាយដោយគ្រឿង

សុគន្ធជាត គឺក្រេះបួងចន្ទន៍ មានក្លិនក្រអូបជាប្រក្រតី, ដល់ចេញទៅនៅព្រៃ សឹងប្រឡាក់ដោយកក់ផង់ធូលី តើនាងឲ្យកូនទាំងពីរទៅប្រឡាក់ប្រឡូសដូច្នេះ ដូចម្តេចកើត? មួយទៀត ទារកទាំងពីរធ្លាប់នៅជាសុខស្រួលមានមនុស្សបក់ផាត់ដោយផ្លិតរោមចៀមចាមរី ទីងរោមកន្ទុយក្ងោក ដោយដៃស្រាល ៗ ជាធម្មតា. ដល់ចេញទៅនៅព្រៃព្រឹក្សា មានតែមូសរបោមរោមខាំ ទាំងទិវារាត្រី, តើកេសិនីនាងបណ្តោយឲ្យកុមារទៅរងលំបាកដូច្នេះ ម្តេចកើត? ។

ព្រះនាងកេសិនីទេវី ដ៏ល្អល្អះសព្វអង្គឥន្ទ្រិយ ទ្រង់ត្រាស់ព្រះរាជសវនីយ ឆ្លើយតបព្រះរាជស្វាមីវិញថា: បពិត្រព្រះកស្តា, សូមទ្រង់ព្រះមេត្តា កុំមានព្រះរាជទុក្ខយ៉ាងនេះឡើយ នាំឲ្យធុកធ្ពូលក្ពលក្តៅក្នុងហឫទ័យ នៃខ្ញុំម្ចាស់ខ្លាំងណាស់! ទោះបីបើខ្ញុំម្ចាស់ស្លាប់ ក៏ស៊ូតែស្លាប់ជាមួយព្រះអង្គ, ត្រង់រស់នៅត្រមោចត្រមង់ ព្រាត់ប្រាសចាកព្រះអង្គទៅនោះពុំបានទេ! ព្រះអង្គទ្រង់ទ្រាំរងទុក្ខលំបាកបានយ៉ាងណា, ខ្ញុំម្ចាស់ក៏ទ្រាំបានយ៉ាងនោះដែរ; ពេលនេះខ្ញុំម្ចាស់ស៊ូតែនាំពកូនទាំងពីរទៅតាមក្រោយព្រះរាជស្វាមី ពុំខាន ។

គ្រានោះ ព្រះមហាសត្វមិនអាចឃាត់ព្រះនាងទេវីបានសោះ ទើបទ្រង់ត្រាស់បណ្ដោយ អនុញ្ញាតឲ្យថា "ហៃមាសពុំអា, បើដូច្នោះ ចូរនាងទៅនៅជាមួយនឹងបងចុះ" ។ លំដាប់នោះ ព្រះនាងទេវីក៏រៀបចំស្បៀងសម្រាប់លៀងជីវិតស្រេចហើយ ព្រះនាងទ្រង់ពាជេយ្យទត្តកុមារ, ព្រះរាជាទ្រង់ពរជេយ្យសេនកុមារ ស្ពាយស្បៀងអាហារដោយព្រះអង្គ បណ្ដើរគ្នាចេញចាកព្រះនគរទៅកាន់ព្រៃ ។

អង្គសម្ដេចព្រះបរមសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទ្រង់ត្រាស់ជាបទព្រះគាថាថា:

យទា ច កេសិនី ទេវី អាហរិត្វា សកំ បុត្តំ
ជេយ្យទត្តំ គហេត្វាន នគរា និក្ខមិ តទា
តតោ សុភមិត្តោ រាជា អំសេ អាទាយ បសិព្វកេ
ជេយ្យសេនញ្ច អាទាយ សកំ បុត្តំ និក្ខមិ

ភិក្ខវេ ម្នាលភិក្ខុទាំងឡាយអើយ, មុខគួរឲ្យអាសូរ ដល់ក្សត្រទាំងបួនព្រះអង្គ ដែលធ្លាប់តែទ្រង់ចំរើនដោយសេចក្ដីសុខក្នុងព្រះសិរីរាជសម្បត្តិ គ្រានោះព្រះអង្គទ្រង់ឃ្លាតចាករាជបុរីដ៏ប្រសើរ ដោយដំណើរពុំសមសោះគឺព្រះនាងកេសិនីរាជទេវី នាំព្រះរាជបុត្រាទាំងពីរ មកប្រជុំគ្នារញ៉ង់ នាង

ទ្រង់ពរួបត្រឹមតែជេយ្យទត្តកុមារ យាត្រាចេញទៅ, សម្តេចព្រះបមបៅសុកមិត្តពង្សា ស្ពាយទៃដោយព្រះអង្សា ព្រះហត្ថាដឹកព្រះហស្តជេយ្យសេនរាជបុត្រច្បង បណ្តើរគ្នាត្រសងចេញទៅទាំងកណ្តាលរាត្រី ដោយសេចក្តីផ្អូកផ្អះទង្គឹះគន្ទុងព្រះរាជឫក ។

គ្រានោះ មហាសត្វទ្រង់ចេញចាកព្រះនគរ ទ្រង់ស្តេចត្រាចរទៅតាមលំដាប់ ស្រាប់តែដល់ស្ទឹងមួយ; ព្រះអង្គមានសេចក្តីនឿយព្រួយពេក ទើបនាំព្រះរាជទេពីនិងព្រះរាជបុត្រាទាំងពីរចូលទៅឈប់សម្រាកព្រះកាយពលក្រោមដើមទន្លាប់មួយដើមក្បែរស្ទឹងនោះ, ទ្រង់បញ្ចុកអាហារចំណីព្រះរាជបុត្រទាំងពីរ ហើយទើបទ្រង់ត្រាស់ព្រះរាជ-ទង្គារថា « ម្នាលនាង, ស្ទឹងនេះជ្រៅណាស់ យើងមិនអាចឆ្លងទៅត្រើយនាយទាំង ៤ នាក់បានឡើយ, កុមារទាំងពីរតូចៗណាស់ យើងទុកឲ្យនៅខាងអាយសិន, បងចម្លងនាងទៅមុន សឹមត្រឡប់មកចម្លងកុមារទាំងនេះជាខាងក្រោយ » ។ ទើបព្រះនាងទេវីទ្រង់បំបៅជេយ្យទត្ត-កុមារ យកសំពត់សាជកក្រាលឲ្យផ្ទំ, លុះជេយ្យទត្តកុមារផ្ទំស្កប់ហើយព្រះនាងទ្រង់ក្រាកឡើងសន្សើមៗ បញ្ចុកអាហារចំណីជេយ្យសេនកុមារ, ព្រះហត្ថាទ្រង់បបោសអង្អែលបើបព្រះសិរសាព្រះរាជបុត្រា ទ្រង់ផ្តាំថា «ហៃកូនពុំង៉ា, ចូរអ្នកកុំប្រហែស, ចូរអ្នករក្សាប្អូន ហ៊ាកូនស្ងួន !

ទំរាំបិតាអ្នកត្រឡប់មកយកវិញ" ។ លំដាប់នោះ ជេយ្យសេនកុមារក្រាបបង្គំទូលព្រះវរបិតាថា "បពិត្រព្រះវរបិតា, បើទ្រង់ស្ដេចទៅបាត់យូរ, ទូលព្រះបង្គំជាខ្ញុំទាំងគូ ជាក្មេងកំព្រាអនាថា នៅនាឆ្នេរស្ទឹង ស្ងាត់ឈឹងទាំងកណ្ដាលអធ្រាត្រ; ដូច្នេះសូមព្រះកូវិនាថស្ដេចកុំយូរពេក, សូមត្រឡប់មកយកទូលព្រះបង្គំជាខ្ញុំទៅឆាប់ៗ" ។ ក្សត្រទាំងពីរព្រះអង្គទ្រង់ព្រះសណ្ដាប់ពាក្យព្រះរាជបុត្រក៏ស្លុតហាក់ដូចជាទីងធ្លាយព្រះឧរា, ទើបព្រះរាជាទ្រង់លួងលោមព្រះរាជបុត្រឲ្យក្សាន្តព្រះទ័យស្រួលហើយ. ទ្រង់នាំព្រះនាងទៅចុះធ្ងូនទទឹងទំហំ ៣ គាវុត; លុះធ្ងូនផុតដល់ត្រើយនាយទ្រង់ឲ្យព្រះនាងទេវីគង់ចាំ ទៀបគល់ឈើមួយដើម ហើយទ្រង់ប្រុងប្រៀបទឹងហែលធ្ងូនត្រឡប់មកវិញ ។

គ្រាដែលព្រះអង្គនាំព្រះរាជទេពីធ្ងូនស្ទឹងទៅ ក្នុងរាត្រីនោះ ដូនជាមានព្រានសំណាញ់ពីរនាក់ អុំទូកទៅចតនៅផ្ទរខ្សាច់ ត្រាច់ទៅក្បែរច្រាំងម្ខាង, ព្រះរាជកុមារទាំងពីរព្រះអង្គ ទ្រង់ព្រះសណ្ដាប់ឮសំដីព្រានសំណាញ់ទាំងនោះគិតស្មានជាបិតារបស់ខ្លួនក៏ស្រែកហៅ ។ ព្រានសំណាញ់ទាំងពីរនាក់ឮហើយ ចូលទៅឃើញកុមារទាំងនោះ ក៏មានសេចក្ដីករុណា, ពយកមួយអង្គម្នាក់ៗ ដាក់លើទូកអុំនាំយកទៅផ្ទះរៀងខ្លួន ។

ព្រះរាជាទ្រង់ត្រឡប់មកដល់, ឡើងផុតពីទឹកមករកព្រះរាជបុត្រទាំងពីរពុំឃើញ ក៏ទ្រង់ព្រះដង្ហោយហៅថា "កូនអើយ, អ្នកនៅឯណា?

បិតាមកយកអ្នកហើយ, កូនអើយអ្នកកុំតូចចិត្ត" ហើយស្ដេចទ្រង់ស្ទុះទៅស្ទុះមករត់រកទាំងរាត្រី; លុះភ្លឺច្បាស់ឡើងព្រះបក្រិពុំបានឃើញព្រះរាជបុត្រត្រង់កន្លែងដែលគង់នៅ ក៏ព្រះបមហៅទ្រង់គង់ផ្ទប់សម្រក់ព្រះអស្សុធារា ជោរជលនេត្រាហូរស្រោក់ញាក់ញ័រក្រហល់ក្រហាយ ក្ដៅសព្វព្រះអង្គកាយ ហើយទ្រង់ព្រះកន្សែងសោកជង្ហោយហៅរកព្រះរាជបុត្រទាំងពីរដរាបដល់ស្គតបាត់ព្រះស្មារតី ។

តមត្ថំ បកាសេន្តោ សត្ថា អាហ សម្ដេចព្រះសម្ពុទ្ធបរមសាស្ដាចារ្យជាម្ចាស់ទ្រង់បានត្រាស់ឡើង ទ្រង់ប្រកាសសេចក្ដីនោះថា

សោ តត្ថ បរិទេវិត្វា ពហុការុញ្ញសញ្ហិតំ
ឧទកតីរំ បុន គន្ត្វា តត្ថេវ បតិតោ ឆមា
សោ រាជា បរិទេវិត្វា ពហុការុញ្ញសញ្ហិតំ
ឧទកតីរំ បុន គន្ត្វា បត្ថេវ បតិតោ ឆមា
សោ រាជា បរិទេវិត្វា ពហុការុញ្ញសញ្ហិតំ
ឧទកតីរំ បុន គន្ត្វា សុរិយោវ បតិតោ ឆមា[1] ។

ព្រះបាទក្រុងសុកមិត្តបរមរាជា ទ្រង់ព្រះកន្សែងសោកអួលអន់ព្រះ[illegible] បោកប្រះព្រះកាយាក្នុងទីនោះ ហើយទ្រង់

១ គាថានេះ លោកស្រង់យកពីវេស្សន្តរជាតកត្រង់មទ្រីបព៌ ។

ស្ទុះរត់ទៅរកព្រះរាជបុត្រឯកំពង់ទឹកទៀត ដោយព្រះទ័យប្រកបដោយសេចក្ដីករុណាច្រើនប្រការ ទ្រង់នឹកស្មានថាក្រែងព្រះរាជបុត្រទាំងពីរនោះលោតចុះទៅក្នុងទឹក; កាលបើរកពុំឃើញ ក៏ទ្រង់ដួលចុះទៅលើផែនដី សន្លប់បាត់ព្រះស្មារតីនៅនាទីនោះឯង; លុះភ្ញាក់ឡើងទ្រង់ព្រះកន្សែងសោកក្នុងទីនោះ ហើយស្ទុះរត់ទៅរកឯកំពង់ទឹកទៀត ដោយសេចក្ដីករុណាចំពោះព្រះរាជបុត្រា ទ្រង់ដួលសន្លប់នៅទីនោះទៀត ដូចជាព្រះចន្ទ្រជ្រុះធ្លាក់ចុះមកលើផែនដី; អគ្គសម្ដេចព្រះនរបតីក្រុងសុកមិត្ត ទ្រង់រឹតតែថ្ងូរព្រះកន្សែងសោកក្នុងទីនោះ ហើយទ្រង់ស្ទុះរត់ទៅរកឯកំពង់ទឹកទៀត ដោយព្រះទ័យប្រកបដោយមហាករុណា ក្សត្រាទ្រង់ដួលសន្លប់ដូចជាព្រះអាទិត្យជ្រុះចុះមកលើផែនដី ។

សម្ដេចព្រះបក្រីទ្រង់ភ្ញាក់ឡើង ទ្រង់ព្រះកន្សែងថ្ងូររៀបរាប់ថា "ឱកូនកំសត់មាសឪពុកអើយ ! កាលនៅស្រុកនាយនៅឡើយ បើបិតាទៅទីណាបាត់មុខមួយដងមួយកាល អ្នកតែងយំស្រែក មើលផ្លូវផ្សាក្អែក; កាលបើបានឃើញបិតាមកដល់ អ្នកទាំងពីរតែងរត់ត្រសងមកទទួល ដូចជាកូនម្រឹគឃើញមេ ក្នុងវេលាកំពុងស្រេកទឹកក្សីរ ក៏ដកករហង់រត់ជម្រង់មកក្រឡឹងជុំវិញ ដោយសេចក្ដីត្រេកអរសេចក្ដីស្រឡាញ់

សុខ ធ្វើចិត្តបិតាឲ្យកម្រើកញាប់ញ័រ, កូនអើយ, ឥឡូវនេះម្ដេចឡើយ បានជាបាត់មុខអ្នក ! អ្នកប្រឹងពួនសំងំអ្វីយូរដល់ម្ល៉េះ? ឱដំណើរអញនេះ ពេញជាធ្ងោយខ្លាំងណាស់ ! ហ៊ានលាកលះចោលកូនតូច តំណូចប៉ុននេះឲ្យនៅឯកឯង ដូចជាមេម្រឹគលៀងកា ឬមេម្រឹគអ្វីនានា ពុំនោះសោតទេ ដូចជាបក្សីញីឬមេសីហៈ ដែលជាប់ជំពាក់ដោយអាមិស គិតតែត្រង់ការប្រឹងប្រែងស្វែងរកអាមិសដោយគិតស្មានថាបានសុខ ហើរផុតពីសំបុក ឬចេញហួសពីលំនៅទៅ ស្រាប់តែកូនតូចៗដែលនៅត្រូវមានអន្តរាយដោយឥតដឹងខ្លួនសោះ ៗ ឱ ! មុខគួរឲ្យស្រណោះដល់កូនទាំងពីរជាទីបំផុត អ្នកធ្លាប់តែរត់មកចាំមើលផ្លូវឪពុកពីចម្ងាយ ដូចកូនខ្ចីនៃមេម្រឹគលៀងកា ធ្លាប់តែរត់ទទួលមេរាដូរោះ, ឥឡូវអញឥតឃើញកូនតូចទាំងពីរនោះសោះ ! កូនអើយ អ្នកនៅឯណា? ហៃកូនពុំងាមាសឪពុកអើយ ទោះបីអ្នកប្រឡាក់ប្រឡូសដោយកក់ផង់ធូលី ឬអាចម៍ដីយ៉ាងណាក៏ដោយ ឲ្យតែអ្នករត់មករកឪពុកចុះ ក៏ឪពុកនៅតែត្រេកអរ, ឥឡូវនេះ ឪពុកឥតឃើញអ្នកសោះ ឲ្យឪពុករស់នៅដូចម្ដេចកើត? ហៃកូនពុំងា, អ្នកឯងដូចជាក្អែកស្ដាំរបស់បិតា; នែបា, អ្នកឯងដូចជាហ្ឫទ័យនៃឪពុក; ឥឡូវនេះ ម្ដាយអ្នកឯងជាស្រីអនាថា មុខជាកំព្រាដេកតែម្នាក់ឯងហើយ" ៗ ព្រះបាទក្រុងសុកមិត្តបរមរាជា ទ្រង់រកព្រះរាជបុត្រាពុំឃើញ ក៏ទ្រង់ស្ដេចចុះទៅឯកំពង់ទឹកវិញ - ទ្រង់ព្រះកន្សែងថ្ងូរសោកាថា

ឥមេ តេ ជម្ពុការុក្ខា វេទិសា សិន្ធុវារិតា
វិធានិ រុក្ខជាតានិ តេ កុមារា ន ទិស្សរេ ។
អស្សត្ថា បនសា ចេមេ និគ្រោធា ច កបិត្ថនា
វិធានិ រុក្ខជាតានិ តេ កុមារា ន ទិស្សរេ(១) ។

ឱ! ឱ, ដើមព្រីងជម្ពូព្រឹកទាំងនេះអើយ មានសំណុំស្លឹកលាស់ដង្គុំដង្គោលពោលមែកបែកទៅសព្វទិសា សឹងដ៏ស្រប ស្រង់យកជាតិជលធារាព្នារទឹកអំពីសមុទ្រ ទាំងរុក្ខជាតិផ្សេងៗ មានច្រើនជាទីបំផុតគួរតែបុត្រអ្នកចូលជ្រក, ម្តេចឡើយ បានជាយើងរកកុមារទាំងនោះពុំឃើញ ។ ឱ! ដើមព្រឹក្សាទាំងឡាយនេះអើយ គឺដើមពោធិ៍បាយ ខ្នុរណាំង ជ្រៃ ខ្វិត សឹងដ៏ដុះប្រកិតជាប់គ្នា ជាមួយនឹងរុក្ខជាតិនានាច្រើនប្រការ ពុំឃ្លាតគ្នា ប្លែកអ្វីតែកុមារក៏បែកបាត់ពីយើងទៅ យើងស្ទាក់រកគ្រប់ផ្លូវពុំឃើញសោះដូច្នេះ ។ (មានត)

---

១ គាថានេះ លោកស្រង់ពីវេស្សន្តរជាតកត្រង់មទ្រីបព្វ ជាគាថាដែលគេធ្លាប់សូត្រជាបទស្មូត។

# រឿងសៅរ៍សោយ

(សិសោរជាតក)

## ព្រះមហាឧត្តមវិជ្ជា ផលញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមគម្រាយសាស្ត្រាស្លឹករិត

(តមក)

---

ស្ងាំងកាំងភ័ន្តកាំងខ្វាំងក្រៃ ញ័រជើងញ័រដៃ ទៃ ៗ គប់គ្នា ។
ខ្វះរស់ខ្វះក្ស័យជន្មា ខ្ទបខ្ទាបចេស្ដា ប្រែពួនប្រែពានរឹករ៉ ។
ស្ដេចដេញអស់ពលទិករ រួតរត់ខ្វាយខ្វរ ពន្ទុកពន្ទឹកពេកក្រៃ ។
ស្ដេចចុះចាកប្រាសាទជ័យ ស្ទុះរត់រៃ ៗ ដល់ដីក្សេត្របៃម្ទុម្ទា ។
ផែលមហាលទ:អស្សពាហន៍ បើកបរលីលា ក្សេត្រាដូចជាឆ្កួតស្មោះ ។
បរសេះទំលាយចំពោះ បុន្នាយរាំងនោះ ក៏ធ្លុះទាំង ៧ ជាន់ ។
ទីនាំងកម្ទាំងរួសពន់ ក្សេត្រថ្ងៃសោភ័ណ ក៏ញាក់កន្ទ្រាក់បរបោះ ។
រីឯមនោម័យនោះ ធ្លាប់តែហៀរហោះ ចំពោះអាកាសវេហាស៍ ។
តែកាលគ្រោះដល់ហើយណា ក៏ធ្វើឲ្យវា ហៀរហោះដូច្នោះពុំបាន ។
ទើបនាំព្រះអង្គទៅឋាន ចាកបុរីហាន ដោយផ្លូវកម្ទាំងឥតបី ។
អស់ពលរបល់ឃ្លាតខ្វី ដេញតាមនរបតី ឥតបីទាន់មួយឡើយណា ។
ព្រះបាទសិសៅរ៍ពជា ចាកនគរា តែមួយព្រះអង្គឯងទៅ ។
ចូលដល់មណ្ឌលព្រៃជ្រៅ ពុំដឹងសៅហៅ លំនៅទីឋានឡើយណា ។

ទៅឆ្ងាយចម្ងាយមាគ៌ា ៣០យោជន៍ណា សុរិយាទន់ទាបល្ងាចថ្ងៃ ។
ស្ដេចបានទៅដល់ដើមជ្រៃ មួយដុះទៀបព្រៃ ត្រឈៃត្រឈឹងសាខា ។
សេះថយកំឡាំងហើយណា ឯមហាក្សត្រា កាយាក៏ទ្រមល្វិតល្ហៃ ។
រីងពោយអស់ទាំងសរសៃ ចុះចាកអាជានេយ្យ អាស្រ័យក្រោមជ្រៃសាខា ។
ស្ដេចអត់ទាំងភោជនា ជេះជោងកាយា សន្ធៃសន្ធឹកទិត្យទៅ ។

ដំណើរព្រះបាទសិរសៅរ៍ ទុកស្វេះឈប់នៅ ថ្ងៃងទៅឯនាងជាយា ។
ដែលគង់គង់នគរ នាងនាថដឹងជា ក្សត្រាចាកចេញទៅបាត់ ។
ទើបអង្គក្សត្រីវរវ័តន៍ ប្រើពលរត់ស្កាត់ ចែកគ្នារត់រកពជា ។
អស់ពលសកលយោធា ស្កាត់រកក្សត្រា រវេតរវាមដោយព្រៃ ។
រកទៅដោយខ្លួនទីទៃ សព្វដងព្រែកព្រៃ ទីទៃ ៗ គ្រប់គ្នា ។
រត់រកដោយដងអាត្មា ដងព្រោះបព្វតា នានាពុំយល់ស្ដេចសោះ ។
អស់ពលយោធាទាំងនោះ រកដោយចន្លោះ កៀនកោះគុម្ពោតតូចធំ ។
តត្រករកក្សត្រឧត្ដម សព្វព្រៃទុរគម ទិសទាំង ៨ សព្វសាយ ។
ខ្លះរកជិត ៗ ជៀងអាយ ខ្លះរកទៅឆ្ងាយ សឹងតែអស់ចិត្តគ្រប់គ្នា ។
ពុំយល់ហើយវិលលីលា ជួបជុំអស់គ្នា មុំមាក្រាបទូលនាងនាថ ។
បេតិត្រយើងខ្ញុំព្រះបាទ រត់រកស្ងាត ដោយព្រោះជន្ទងដងព្រៃ ។
ពុំឃើញអម្ចាស់ឡើយនៃ យើងខ្ញុំវៃព តត្រករករកពុំយល់ ។
រកសព្វទូទីឋាកថ្កល់ អស់ចិត្តពុំយល់ យើងខ្ញុំសាយដៃស្ងោះ ។

រកសត្វពុំមានបន្ទោះ ព្រៃព្រឹកសានៈគ្រោះ ឥតខ្វះបន្ទោះត្រង់ណា ។

ពុំបេរតាមតែមេត្តា យើងខ្ញុំគ្រប់គ្នា ស្វះស្វែងស្កាត់រកពុំយល់" ។

### បទព្រហ្មគីត

ឯនាងនាថជាយា ស្តាប់វាចាអស់រេហ៍ពល
ទូលថារកពុំយល់ នាងសែនខ្វល់ក្នុងឧរា ។
ក្នុងទ្រូងដូចគេបុក កើតជាទុក្ខឈឺខ្លោចផ្សា
ញាប់ញ័រអស់អង្គា ព្រះជាយាទ្រង់កន្សែង ។
ឯអស់ទាំងស្រីស្នំ សឹងទួញយំពុំក្តែង ។
ផ្តេកផ្តួលនៅលើល្វែង ប្រាសាទឯងឥតមានស្បើយ ។
ខ្វះសោយសោកដោយដី ទួញបក្រឹសូរល្វេងល្វើយ
នទៀលធាក់ដីហើយ ក្នុងទ្រហឹងហាក់ហឹងយំ ។
ឯនាងនាថកាន្ត – ទេវីតនមហេសីធំ
សោយសោកក្សត្រឧត្តម ឧរាក្រៃខ្លោចផ្សាក្រៃ ។
ខាងសោកៗសង្រេង ឈឺកន្ទេងក្នុងហ្ឫទ័យ
សង្រេងរេងសាង្រៃ ម៉េះសមក្សយជន្ទុពុំលែង ។
ព្រះឧស្តនាងទួញទៅ "ឱ! ព្រះចៅជាគម្ពែង
"ឱ! សមស្តេចរង្វើង ចាកកន្ទ្វង់ទៅឋានណា ។
ខ្ញុំឲ្យគេរត់រក ដោយពង្រងឆកព្រៃព្រឹក្សា

ពុំយល់ព្រះកជា ស្តេចលីលាទៅណាបាត់ ។
ឱ ! ព្រះវៀមក្សត្រថ្លៃ ធ្លាប់គង់ញប្រាសាទរ័តន៍
មន្ត្រីគាល់ហ្លួបថ្វាត់ ឥឡូវស្ងាត់សូន្យជ្រងំ ។
ឃើញតែមុខមន្ត្រី បាត់នរបតីថ្លៃឧត្តម
ព្រះអើយ ! ខ្ញុំប្អូនក្រំ ក្រំចង្អៀតណែនស្មើរធ្លាយ ។
ឱ ! ពីថ្ងៃនេះទៅ សមប្អូននៅជាមេម៉ាយ
ទុក្ខអើយឥតរសាយ សព្វាក្រិតឥតបីល្ហែ ។
ពីដើមបានព្រះអង្គ ស្តេចតែងគង់ៗលើគ្រែ
ឥឡូវនេះឯងឯ ឃើញតែគ្រែបាត់ព្រះអង្គ ! ។
ប្អូនឃើញតែកន្ទេង ដែលស្តេចស្តែងតែងធ្លាប់គង់
ឥឡូវពុំយល់យង់ តើស្តេចគង់គង់ឋានណា ។
ប្អូនឃើញតែដំណាក់ បាត់វៀមរ័កវែងស្នេហា
ពុំដែលអាក់ចិន្តា ឲ្យប្អូនជាទុក្ខដល់ម្តង ។
ព្រះអង្គសោយសម្បត្តិ សម្បូណ៌ក្តាត់សុខកន្ទង
អស់ស្តេចដទៃផង នាំសួយវែរថ្វាយបង្គំ ។
ឥឡូវនេះឯងណា បាត់រាជាសូន្យជ្រងំ
ខ្ញុំប្អូនកើតទុក្ខធំ ហាក់ដូចភ្នំរលំលើ ។
ឱ ! ព្រះវៀមរ័តន៍ថ្លៃ រស់ប្តីក្ស័យប្អូនសើរើ

ឥឡូវព្រះអង្គតើ ជាដូចម្ដេចប្អូនពុំដឹង ៗ
ប្អូនឲ្យគេរត់រក ស្កាត់ទៅមកឥតដំណឹង
បាត់ឈ្មោះសោះសូន្យឈឹង ប្រុសព្រលឹងទៅឋានណា ៗ
ព្រះអង្គស្ដេចប្រាសទៅ ឲ្យប្អូននៅអនាថា
ស្ដេចត្រាច់ដោយមាគ៌ា តែពីរគ្នានឹងអាជានេយ្យ ៗ
ស្ដេចព្រាត់ពីទ្រូងប្អូន មសារសូន្យទៅទីទៃ
ប្អូនមើលផ្លូវរៃ រំពឹងគិតក្រែងស្ដេចដល់ ៗ
ឱ! ពេលថ្ងៃនេះហើយ កាលណាឡើយនឹងបានយល់
ប្អូនឃើញតែខ្មើយខ្មល់ ប្អូនពុំយល់ព្រះកាជា ៗ
ឱ! ហេតុតែកម្មកាយ ពីព្រេងនាយតាមទាន់ណា
ធ្វើឲ្យព្រះកស្ដា ភ័ក្ដិបន្ទាត់គិតផ្សេងទៅ ៗ
បណ្ដាលឲ្យព្រះទ័យ ជាទុក្ខក្រៃកើតមួយមៅ
បណ្ដាលឲ្យក្ដួលក្ដៅ ក្នុងព្រះទ័យធ្វើមប្រែមាត់ ៗ
ឱ! កម្មៗ ពីព្រេង ពុំវេងទៅណាបាត់
ធ្វើឲ្យមហាក្សត្រ ចាកចេញបាត់ផ្លូវបេះណា " ៗ
នាងសោកៗ សង្រែង ឈឺកន្ទេញរែងខ្លោចផ្សា
យូរបន្ដិចជាយា នាងបន្ទោទុក្ខសោកស្រាន្ត ៗ

ដំណើរនេះស្ងះនៅ នឹងថ្លែងទៅតាមដោយបាន
អំពីមហាក្សត្រក្សាន្ត ដែលស្ដេចឈប់ម្ចប់ព្រះវៃផ្ទ ៗ (មានត)

# រឿងសាមកុក

## កណ្ឌទី ១៩

### ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

ចៀយ៉ុកថាគ្រាដែលឡៅពីគេចរត់ពីលីប៉ោមកជ្រកនៅនឹងលោក ខ្ញុំបាទយល់ឃើញថាឡៅពីជាទីចំរូងចំរើនទៅខាងមុខ ខ្ញុំបាទក៏បានជំរាបលោកជារឿយៗថា ឲ្យសំឡាប់ឡៅពីចេញ លោកមិនធ្វើតាមខ្ញុំបាទ ក្រោយនោះលោកឲ្យឡៅពីធ្វើជាចៅហ្វាយស្រុកអ៊ីជីវ រួចត្រឡប់ទៅនៅស្រុកសៀវផាយ ហើយឡៅពីបែកពីលីប៉ោមកទីពឹងលោកវិញ ដែលលោកជឿទុកចិត្តឲ្យឡៅពីធ្វើជាមេទ័ពលើកចេញទៅគ្រានេះ ឧបមាដូចលែងខ្លាឲ្យទៅក្នុងព្រៃឬលែងត្រីឲ្យចុះទៅក្នុងទឹកទន្លេ តំណទៅឯមុខឡៅពីក៏គង់នឹងមានកំឡាំងច្រើនឡើង លោកនឹងបង្ក្រាបឲ្យរាបទ័ពទៅវិញក៏កម្រណាស់ ។

គុយកែជំរាបចូច្ចូថា ដែលលោកមិនបានសម្លាប់ទៀតីចេញ ហើយយកទុកប្រើប្រាស់នោះគួរហើយ តែឥឡូវលោកប្រើឲ្យទៀតីចេញទៅធ្វើជាមេទ័ពនោះមិនត្រូវសោះ ព្រោះបុរាណមានពោលទុកថា បើអ្នកឯណាជាមេទ័ពគ្មានអាជ្ញាសិទ្ធិតែម្ដង ក៏មានចិត្តកំរើកយ៉ាងធំទូលាយដូចបានធ្វើដល់ ១ ពាន់ដង ខ្ញុំបាទយល់ឃើញថា ទៀតីមានកុំឡាំងទៀងនឹងប្រែចិត្តចេញពីលោក តទៅមុខលោកនឹងបានសេចក្ដីព្រួយលំបាកព្រោះទៀតីជាប្រាកដ ឲ្យលោកត្រិះរិះគិតឲ្យមាំមួនចុះ ។

ចូច្ចូបានស្ដាប់ធៀយ៉ុកនឹងគុយកែ និយាយរាប់រៀបដូច្នោះក៏ឲ្យភ័យស្លុតក្នុងចិត្ត ទើបចាត់ប្រើទាវធូឲ្យលើកទាហានសេះ ៥០០ ទៅតាមទៀតី បើទាន់ហើយឲ្យប្រាប់ឲ្យត្រឡប់មកវិញ ។ ទាវធូក៏លើកទាហានសេះ ៥០០ បរយ៉ាងប្រញាប់ទាំងយប់ទាំងថ្ងៃ លុះទៅដល់ជិតកងទ័ពទៀតីហើយ ទៀតីក៏ក្រឡេកមើលក្រោយឃើញផង់ធូលីដីហុយទ្រលោមឡើង ព្រួសន្ធឹកដើរសេះបោលប៉ះពារលើគ្នាគឹកកង ក៏និយាយនឹងគួនអ៊ូ, តៀវហ៊ុយថា "ដែលព្រួសន្ធឹកមកពីក្រោយនោះ មុខជាចូច្ចូប្រើឲ្យលើកទ័ពមកតាមយើងឲ្យត្រឡប់ទៅវិញជាប្រាកដហើយ" ថាហើយក៏បញ្ឈប់កងទ័ព ហើយចាត់គួនអ៊ូ, តៀវហ៊ុយឲ្យរាកងទ័ពឈរកាន់អាវុធសងខាងផ្លូវចាំការពារអន្តរាយ ។

លុះទាវធូបរសេះមកដល់ឃើញទាហានទៀតីត្រៀមប្រុងខ្លួនដូច្នោះ ក៏លោតចុះពីលើសេះដើរទៅកណ្ដាលកងទ័ពតែម្នាក់ឯង ហើយនិយាយ

នឹងឡៅពីថា ឥឡូវមហាឧបរាជប្រើខ្ញុំបាទមកតាមអញ្ជើញលោកឲ្យលើកកងទ័ពត្រឡប់ទៅស្រុកហូគោវិញ នឹងបានបញ្ជាក់សេចក្ដីដល់លោកទៀត ៗ ឡៅពីក៏ឆ្លើយតបទៅទៅផូវិញថា កាលមហាឧបរាជនាំយើងទៅក្រាបបង្គំគាល់ព្រះចៅហៀនតេ សុំព្រះរាជទានឲ្យយើងធ្វើជាមេទ័ពលើកពលទៅស្ទាក់រាំយកកងទ័ពអ៊ុនស៊ុត ព្រះចៅហៀនតេក៏ទ្រង់ព្រះរាជានុញ្ញាត យើងក៏បានក្រាបថ្វាយបង្គំលា ទាំងមហាឧបរាជឯងក៏បានចាត់ចែងប្រគល់ពលទាហានឲ្យយើង ហើយបង្គាប់ប្រាប់ខរាជការដល់យើងគ្រប់ប្រការ បានជាយើងលើកទ័ពចេញមកតាមព្រះរាជតម្រាស់ព្រះចៅហៀនតេ ឥឡូវមហាឧបរាជត្រឡប់ឲ្យមកតាមយើងឲ្យវិលទៅវិញ បើប្រសិនយើងនឹងវិលទៅវិញវេលានេះ ក៏នឹងមានសេចក្ដីខុសពីព្រះរាជតម្រាស់ព្រះចៅហៀនតេ បើដូច្នេះប្អូអេកវិលទៅយកសេចក្ដីសមគួរប្ដឹងមហាឧបរាជមុនចុះថា បើកាលណាយើងធ្វើសង្គ្រាមសម្រេចហើយគង់នឹងលើកកងទ័ពត្រឡប់ចូលទៅក្រាបទូលព្រះចៅហៀនតេ ហើយនឹងនាំសេចក្ដីពីកិច្ចរាជការប្ដឹងមហាឧបរាជឲ្យជ្រាបតាមការ ៗ

ទៅផូបានស្ដាប់ពាក្យឡៅពីនិយាយដូច្នោះក៏គិតថា "កាលបូធូប្រើអញមកនោះនឹងបានដាក់កំហិតថា បើឡៅពីមិនព្រមត្រឡប់វិលទៅវិញឲ្យអញកំហែងបង្ខំចាប់នាំខ្លួនឡៅពីឲ្យបានយកទៅក៏ឥតអគ្គីមាន ដែលឡៅពីនិយាយមកដូច្នេះ ក៏ត្រឹមត្រូវតាមព្រះរាជតម្រាស់ណាស់ បើដូច្នេះ

ត្រូវតែអញត្រឡប់វិលទៅជំរាបចូឆូវិញសិនចុះ បើចូឆូនឹងឲ្យធ្វើប្រការម្ដេច សុំអញវិលត្រឡប់មកវិញធ្វើតាមបង្គាប់នោះជាក្រោយ" លុះគិតដូច្នោះ ហើយក៏លាឡៅពីនាំទាហានទាំងអស់ ស្រុតត្រឡប់ចូលទៅក្រុងហ៊ូតោវិញ ចូលទៅជំរាបចូឆូតាមពាក្យឡៅពីនិយាយនោះគ្រប់ប្រការ ។ ចូឆូបានស្ដាប់ក៏ទាល់គំនិតបេះតែគិតវិតក្ក ធៀយ៉ុកនឹងគុយកែក៏និយាយជំរាបចូឆូថា ដែលលោកប្រើឲ្យទៅតាមឡៅពីហើយឡៅពីមិនព្រមមកនោះ លោកឃើញច្បាស់ដូចពាក្យខ្ញុំបាទជំរាបមែនឬទេ? ។ ចូឆូតបថា យើងបានចេញវាចាប្រើឡៅពីទៅហើយ បើនឹងបង្ខំឲ្យត្រឡប់វិលមកវិញក៏បាន តែនឹងឃើញថា យើងវាចាមិនជាសត្យវិបត្តិពាក្យសំដីហៅថាពាក្យ ២ សូម្បីឡៅពីមានចិត្តកំរើកគិតប្រទូសរ៉ាយនឹងយើងវិញ យើងក៏មិនត្រូវខ្លាចអ្វីនឹងចូដៃឡៅពីប៉ុណ្ណោះ ប្រការ ១ ទៀត យើងក៏បានប្រើដូឡេងនឹងឡេដៀវឲ្យកាន់កាប់ទៅជាមួយផង បើឡៅពីប្រែចិត្តចេញពីយើងយ៉ាងណា គង់តែដូឡេងនឹងឡេដៀវមានសំបុត្រមកដល់យើងជាអាថ៌កំបាំងមិនខាន ។

(មានត)

# នលៈ និង ទមយន្តី

### រឿងព្រេងប្រទេសឥណ្ឌា

## អ្នកស្រី ស្រិន-សារិយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យភ្នំពេញ

*ប្រែពីភាសាបារាំងមកជាភាសាខ្មែរ*

(តមក)

---

### វគ្គទី ២១

យប់មួយ ព្រះបាទនលៈនាំព្រះនាងត្រេចចូលក្នុងព្រៃញឹក ហើយទ្រង់នឿយព្រះអង្គនឹងដើរឆ្ងាយ ៗ ព្រះនាងទមយន្តី ទ្រង់នឿយហត់ខ្លាំងដោយយាងដើរផ្លូវឆ្ងាយពេក ក៏ទ្រង់ប្រែះព្រះអង្គផ្ទំលក់នៅនាគល់ឈើ ៗ ព្រះបាទនលៈទ្រង់ព្រួយព្រះហឫទ័យខ្លាំងពេកក៏ផ្ទំពុំលក់ ទោះបីទ្រង់អស់ព្រះកាយពលយ៉ាងនេះ ក៏ទ្រង់ចេះតែព្រះតម្រិះរំពឹងទៅៗ ថា "តើអញដើរលុកលុយក្នុងព្រៃនេះធ្វើអ្វី ចុះបើសិនជាស្លាប់ទៅ មិនប្រសើរជាជាងនៅរស់ដោយវេទនាយ៉ាងនេះឬ? តើការដែលធ្វើកុំឲ្យព្រះនាងទមយន្តីស្គាល់នូវសេចក្តីវេទនាយ៉ាងក្រៃលែងនោះ មិនមែនជាករណីយកិច្ចរបស់អញទេឬ? ឯព្រះនាងរងសេចក្តីវេទនាដោយសារតែអញប៉ុណ្ណោះ, តើព្រះនាងដែលប្រកបដោយសេចក្តីស្មោះត្រង់យ៉ាងនេះត្រូវទទួលសេចក្តីទុក្ខ សេចក្តីនឿយព្រួយជារង្វាន់ទៅវិញឬ? បើសិនជាទុកព្រះនាងឲ្យនៅតែឯង ប្រហែលជាព្រះនាងមានភ័ព្វនឹងទៅរកប្រទេសព្រះវរបិតា

ឃើញ, បើសិនជាអញចេះតែនៅជាមួយនឹងព្រះនាងៗ ច្បាស់ជារងវេទនាលើសអ្នកកំសត់ទុគ៌តផងទាំងពួង បើអញដើរចេញចោលព្រះនាងនៅទីនេះទៅ មានថ្ងៃណាមួយព្រះនាងនឹងបានសប្បាយ ឱ! កែវទេមយន្តិកិច្ចរបស់បងត្រូវតែលានាងក្នុងពេលនេះ" ត្រាស់ហើយព្រះអង្គក្រោកឡើង ហើយទ្រង់ហែកសំពត់គំពង់ ដែលទ្រង់ដណ្តប់ទាំងពីរព្រះអង្គនោះជាពីរ ដោយមិនធ្វើឲ្យព្រះនាងភ្ញាក់ទេ ទ្រង់យកសំពត់នោះ ១ កំណាត់ហើយ យាងចេញយ៉ាងរហ័ស ។ ប៉ុន្តែបន្តិចក្រោយមក ព្រះអង្គទ្រង់ញ៉រចំប្រប់ដោយទឹកអាល័យព្រះនាង ហើយក៏ត្រឡប់យាងចូលទៅជិតព្រះនាងវិញ ។ លុះព្រះអង្គឃើញព្រះនាងនៅផ្ទំលក់ដោយស្រួល ព្រះអង្គក៏ទ្រង់ព្រះកន្សែងសោកា ហើយទ្រង់នឹកក្នុងព្រះហឫទ័យថា:

ឱ! កែវវរមិត្តល្អឥតខ្ចោះ　គួរឲ្យសោមនស្សអស់ពិចិត្រ
សូម្បីព្រះពាយព្រះអាទិត្យ　មិនដែលទាស់ចិត្តនឹងកញ្ញា ។
មានកក្រិញញឹមចេញរស្មី　គួរឲ្យមេត្រីអ្វីម៉្លេះណា
កាលកើតក្នុងព្រៃតែឯកា　ម៉្លេះសមជីតាញ៉រចំប្រប់ ។
នាងត្រេចក្នុងព្រៃសម្បុរសត្វ　សាហាវខ្លាំងក្លាត់វេលាយប់
មានទាំងពស់ពិសមកប្រសប់　សូមព្រះម្ចាស់កត្តជួយនាងណា ។
ព្រះនាងប្រកបលក្ខណ៍ឧត្តម　ទេវតាគួបធំក្នុងលោកា
សូមជួយទ្រទ្រង់កែវកនិដ្ឋា　វៀរលាជីវាត្រឹមហ្នឹងអើយ! ។

រៀមមិនគេចចករណីយកិច្ចរៀមឡើយ ប៉ុន្តែដោយព្រះនាងប្រកបដោយគុណធម៌ដ៏ឧត្តម ព្រះនាងនឹងបានសម្រេចនូវសេចក្ដីសុខ រៀមលាហើយ ទមយន្តីស្រីមាសបង!” ត្រាស់ហើយព្រះអង្គក៏យាងចេញទៅឆ្ងាយម្ដងទៀត ប៉ុន្តែព្រះអង្គនៅតែវិលត្រឡប់មករកព្រះនាងវិញ ទោះបីទ្រង់ខំកាត់ព្រះទ័យយ៉ាងណា ក៏ទ្រង់នៅតែរកកម្លាំងនឹងលះបង់ព្រះនាងពុំបាន, ទ្រង់យាងទៅហើយត្រឡប់ចូលមកវិញបីបួនដង ៗ ក្រោយបង្អស់ព្រះបាទនាលៈ ទ្រង់បង្ហូរទឹកព្រះនេត្រសស្រាក់ ហើយយាងចូលព្រៃជ្រៅបោលព្រះនាងទមយន្តី ដែលនៅផ្ទុំលក់តែម្នាក់ឯងក្នុងកណ្ដាលព្រៃ ៗ

## វគ្គទី ៤២

ព្រះនាងផ្ទុំស្កប់ស្កល់ ក៏តើនឡើងដោយភិតភ័យ ហើយក្រឡេករកមើលព្រះបាទនាលៈ ដោយឆ្ងល់នឹងមិនឃើញព្រះអង្គ ៗ ព្រះនាងខំស្រែកហៅព្រះអង្គ តែពុំឮសូរឆ្លើយ ៗ នៅពេលនោះ ព្រះនាងទតយល់សំពត់ដាច់បាត់មួយកំណាត់ ព្រះនាងទ្រង់សោយសោកជាខ្លាំងថា: “ឱ! ព្រះនាល ម្ចាស់ប្អូន! សេចក្ដីហ៊ានយាងទៅបោលប្អូន ឲ្យប្អូននៅក្នុងព្រៃស្ងាត់ជ្រងំតែម្នាក់ឯង, ខ្ញុំម្ចាស់បានដឹងច្បាស់ហើយថាព្រះអង្គស្រឡាញ់ខ្ញុំម្ចាស់ណាស់ ហើយព្រះអង្គបានសច្ចាថានឹងមានព្រះទ័យស្មោះត្រង់នឹងខ្ញុំម្ចាស់ជាដរាប ចុះហេតុម្ដេចបានជាព្រះអង្គដាច់ព្រះទ័យយាងទៅបោលខ្ញុំម្ចាស់ដូច្នេះ? ខ្ញុំម្ចាស់ផ្ទុំលក់ដោយគ្មានបារម្ភអ្វីបន្តិចសោះ

ហើយព្រះអង្គយាងចោលខ្ញុំម្ចាស់ ៗ មិនដឹងជាស្ដេចយាងទៅទីណា, តើព្រះអង្គមិនចាំពាក្យដែលទ្រង់បានសច្ចាចំពោះមុខស្ដេចចតុលោកបាលទេឬ? តើឲ្យខ្ញុំម្ចាស់រស់នៅម្ដេចបាន បើព្រះអង្គបែកឆ្ងាយពីខ្ញុំម្ចាស់ដូច្នេះ?" ។

រួចស្រាប់តែព្រះនាងឈប់ទ្រង់ព្រះកន្សែងទៅវិញ ហើយទ្រង់ព្រះសំរួលចាំងទះព្រះហស្ដផង ព្រះនាងទ្រង់ស្រែកថា: "ឳ ខ្ញុំម្ចាស់ដឹងហើយ ព្រះអង្គលែងវិតក្កទៀតហើយ ដើម្បីនឹងធ្វើកុំឲ្យខ្ញុំម្ចាស់សង្ស័យព្រះអង្គទ្រង់ក្រសាលបិទពួននឹងខ្ញុំម្ចាស់ ព្រះអង្គមុខតែទៅពួនក្រោយដើមឈើនោះហើយ, ខ្ញុំម្ចាស់ឃើញហើយ ព្រះនាល:! ដូច្នេះ បើកាលណាខ្ញុំម្ចាស់ហៅ ព្រះអង្គត្រូវឆ្លើយកុំខាន សូមទ្រង់ព្រះសណ្ដាប់ខ្ញុំម្ចាស់" ហើយព្រះនាងទ្រង់ស្រែកហៅ ហៅស្ដេចដោយបន្លឺសព្រះសូរសៀងថា: "នាល:! នាល:!" សំឡេងព្រះនាងកាន់តែឮពីរពងខ្លាំងឡើង ៗ ប៉ុន្តែគ្មានឮសូរឆ្លើយមកវិញសោះ ព្រះនាងក៏ពោលបន្ទោសថា: "នាល: កំណាច! កុំទ្រង់ក្រសាលដូច្នេះទៀត ព្រះអង្គមិនជ្រាបជាខ្ញុំម្ចាស់ភ័យទេឬ? ព្រះអង្គមិនទ្រង់យល់ជាខ្ញុំម្ចាស់សោកទេឬ? ស្ដេចយាងមកជិតខ្ញុំម្ចាស់ឲ្យឆាប់ឡើង ខ្ញុំម្ចាស់មិនមែនយំដោយអាណិតខ្លួនខ្ញុំម្ចាស់ទេ គឺខ្ញុំម្ចាស់អាណិតដល់ព្រះអង្គដែលសេចក្ដីស្រេកឃ្លានខ្លាំងខ្ញុំនឿយណាយក្នុងព្រះអង្គ តើព្រះអង្គនឹងទៅជាយ៉ាងណាទៅ! បើគ្មានខ្ញុំម្ចាស់នៅលួងលោមជិតព្រះអង្គនៅពេលដែលទ្រង់រងទុក្ខវេទនា" ។

(មានត)

# ដំណើរតាមខ្យល់ក្នុងកាផ្តារៈ

## លោក ផេង-ជ្រឹវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

*ប្រែពីភាសាបារាំងមកជាភាសាខ្មែរ*

(តមក)

---

## ៣ — អំពីបម្បាំង

*ពេលវេលាចេះតែកន្លងទៅ ៗ នារីទាំងពីរមិនបានចេញទៅណាឆ្ងាយឡើយ កិច្ចរវល់ជាច្រើននាំឲ្យនាងនៅតែជិតម្តាយក្នុងទីសំណាក់ គ្មានការណ៍អ្វីធំដុំល្មមយកជាកស្តុតាងបានទេ ក្រៅពីកំដៅព្រះអាទិត្យ ៗ*

*ព្រឹកមួយ នាងឡីឡាទៅដួតទឹកជ្រោះដែលធ្លាប់ដួត ហើយក្រឡេកទៅក្រៅប្រហែលដូចជាឃើញកងមនុស្សម្នាក់ ស្លៀកពាក់ស៊ីប្រែពួននៅជាចន្ទោះដើមត្នោតពីរដើម នាងលួចសំឡឹងសង្កេតឲ្យច្បាស់មួយស្របក់ ឃើញក្បាលជួតឆ្នូត នឹងសំពត់មានតម្លៃលេចប្រាកដឡើងតាមចន្ទោះដើមត្នោត ហើយឈរសំឡឹងទៅជើងមេឃ ៗ មុខហ្នឹង រាងហ្នឹងនាងដូចបានឃើញម្តង កាលដែលអ្នកជិះសេះពីរនាក់ ដេញតាមនាងនឹងបងនាងរហូតមកដល់ទីសំណាក់ ហើយគេធ្វើអ្វីមិនកើតដោយខុសច្បាប់ ៗ លុះដឹងជាក់ដូច្នោះ ឡីឡាស្ទុះរត់ចេញពីទឹកមករកទីអាស្រ័យដោយស្ងៀមស្ងាត់អាក់ខានមិនបានដួតទឹកលេងកំសាន្តក្នុងពេលព្រហាមដែលជាពេល*

ត្រជាក់ សម្រាប់ធ្វើសាច់ឈាមឲ្យឡើងពណ៌ស្អាត ។ ចំណែកខាងជីវភាពបេះតែប្រព្រឹត្តទៅ មានអាការខាងក្រៅជាសុខសាន្តត្រាណ ។

ពួកប្រុស ។ ថ្ងៃល្ងាចត្រឡប់ចូលមកវិញ នាំគ្នាទៅជិតបរលោកតាម៉ាព្រុក អំពីកិច្ចការដែលអាត្មាបានធ្វើអ្វីៗ ខ្លះពីថ្ងៃ ។

កូនក្រមអ្នកដើរទេសទាំងឡាយ មានមនុស្សធ្វើការច្រើនបែប គឺមានតាំងពីមនុស្សអ្នកមុជទឹកការយកផ្កាំងផ្កាថ្ម នៅស្រុកទីប៉ូលីជាដើមឡើងទៅ កាលណាការបានផ្កាំងផ្កាថ្មច្រើនហើយ ក៏យកមករចនាជាគ្រឿងប្រើប្រាស់ផ្សេងៗ យ៉ាងទន់ស្អិតល្អ · មានគ្រូពេទ្យបេះយកខ្ទឹមក្រស្នានឹងផ្កាកូឡាបមកស្ងួតបំពាញយកជាតិធ្វើជាម្សៅ ដើម្បីទុកសម្រាប់តែងកាយទឹងវត្ថុពីវណ្ណស្រីៗឲ្យនៅគង់វង់បានល្អ ហើយបេះធ្វើម្សៅក្រអូបខ្លះទៀតសម្រាប់ឲ្យស្រីចាស់ៗលាបទៅ ត្រឡប់មានសម្បុរដូចនារីអាយុ ២០ ឆ្នាំ អ្នកធ្វើជំនួញសំពត់ស៊ុតក្លាតស្បែកសម្ពាប់ហើយសំពត់សូត្រ មកចាំទទួលនៅស្រុកទីប៉ូលីអំពីអ្នកជំនួញមកពីប្រទេសអឺរុប ។

មនុស្សទាំងនេះ សុទ្ធតែជាអ្នកធ្លាប់ប្រព្រឹត្តការចិញ្ចឹមជីវិតដោយខ្នងសត្វអូដ្ឋកង់វាលកន្តារៈ កណ្ដាលថ្ងៃក្ដៅ បានបទះទីក្រុងតែមួយក្តៗ ។ ម្ល៉េះហើយគេច្រើននិយាយបំផ្លើសបញ្ចេញបញ្ចូលខ្លះ អំពីភោគសម្បត្តិដែលគេបានឃើញ អំពីនាម៉ឺនតូចធំដែលមានសេចក្ដីពប់អានដល់គេអំពី

អំពីប្រាសាទដែលគេបានឃើញ ៗ តាមការណ៍ពិត គឺគេច្រើនតែបង្កើតដោយខ្លួនឯង ដើម្បីនិយាយឲ្យពីរោះដល់ត្រចៀកលោកតាម៉ាព្រុក ចូលចិត្តស្តាប់ដោយសេចក្តីគោរព ។ វេលាល្ងាចកាលណា គេដែលបរិភោគស្ងប់ស្ងល់នូវបាយៈភាគនឹងសាច់ចៀមអាំងហើយ គេនាំគ្នាអង្គុយជុំគន់ចាំស្តាប់គេនិយាយរឿងដំបៃក ៗ ។ កាលណាគេនឹករំពឹងដោយស្រមាក់ស្រម៉ៃយនូវកំផែងប្រាសាទនូវទីក្រុងប្រកបដោយសម្បត្តិផ្សេង ៗនូវរូបស្រីល្អ ៗ នូវមនុស្សប្រកបដោយទឹកមុខរីករាយ នូវបាវព្រាវចិត្តស្លូតត្រង់ គឺជាបើពោលដោយសង្ខេប គឺជារឿងដែលធ្វើឲ្យអ្នកចរាចរក៏ទាំងប៉ុន្មានដែលធ្លាប់តែដេកលើកន្ទេល ឬដេកតែនឹងដីក្រោមដំរំសំពត់ប្រកបដោយភ័យអំពីពស់ ក្អែប ខ្យាដានិច្ច ហើយមិនស្គាល់អ្វីក្រៅពីរលកគន្តារៈ ស្តាប់ពុកាលណា មានក្អែកក្រឡង់ ទឹកកោត ទឹកចង់ ទឹកសប្បាយដោយសារផង រួចទើបពួកអ្នកចរាចរក៏សុំឲ្យនាងឡូឡាច្រៀងបង្ហើយកិច្ចចុងក្រោយ ដែលមានសំឡេងដ៏បរិសុទ្ធ អាចញាំងចិត្តបុរសទាំងឡាយឲ្យពេញបរិបូណ៌ ៗ

នាងច្រៀងរំលឹកអំពីរឿងកាមរាគ នឹងមរណកម្មដែលជាអនិច្ចតាធម៌ ជារឿងដែលតាំងពីយូរណាស់មកហើយ គេតែងទុកជាទំនុកមួយរបស់អ្នកស្រុក ជាទំនុករបស់សាមញ្ញជន ៗ

សំឡេងនាង តែស្រែកច្រៀងឡើងកាលណា អាចធ្វើឲ្យកត្រៃប្រ· កបដោយសេចក្តីរំភើប ស្រណោះស្រណោកលន្លង់លន្លោច ។ សំឡេងនាងជាអាហារមានឱជារសដល់ប្រាជ្ញាមឹងចិត្តនៃបុរសស្ត្រី ដែលចាស់មុនអាយុព្រោះការងាររដ៏យ៉ាប់លំបាកក្នុងកលកន្ទារៈ ។ សំឡេងនាងមានអានុភាពអាចកំចាត់បង់នូវទឹកមុខអាក្រក់ កើតមកអំពីការនឿយហត់ក្នុងវេលាថ្ងៃចាលបាន ។

ចំណែកពួកអ្នកដើរទេស គឺបណ្ដោយចិត្តឲ្យអណ្ដែតតាមសូរនៃចំ-រៀងនាង គេបណ្ដែតដួងវិញ្ញាណឲ្យស្ទុះ ទឹកទៅស្ថានណាមួយជាវិជ្ជមាន-ភាព ទឹកដល់អ្នកក្រខ្សត់គ្មានគណៈ ដើរជួញដោយកលកន្ទារៈគ្មាននាយគ្មានបាវបំរើ គឺជាស្ថានដែលមានតែសុណ្ឋានរូបដូចព្រះបន្ទូ ទឹងស្លូតចិត្តសប្បុរស ចូលចិត្តធ្វើការកុសល ។

ព្រះអាឡ្យស់ក៏ជួយគេទាំងនោះឲ្យបានសុខស្រួល ។

គឺថាក្នុងព្រៃស្ងាត់ មានតែវាយោបក់មកពីកលកន្ទារៈ មានតែពន្លឺផ្កាយលើមេឃ ទឹងសូរចំរៀងដែលធ្វើឲ្យគណៈនេះបានអាស្រ័យដំណេកជាសុខឥតមានចលាចលអ្វីឡើយ ។

ចំណែកទំនុកបន្ទូរដ៏ស្រងេះស្រងោច ចេញបន្តការដឹកពីមាត់នាងក្រមុំ ដែលមានរូបយ៉ាងស្អាតដូចជាផ្កា ។

(មានត)

# បរិយាយពីការសាងវាលុកចេតិយ (ពូនភ្នំខ្សាច់)

របស់លោក ចាប - ពិន

---

តាំងនាមក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ខ្ញុំសូមបរិយាយពីការកសាងវាលុកចេតិយ (ពូនភ្នំខ្សាច់) ដើម្បីរលឹកដល់ទំនៀមនេះជូនជាសណ្ដាប់បងប្អូនរួមជាតិ ដូចតទៅខាងមុខ ៖

ចេតិយដែលគេសាងដោយដីខ្សាច់សុទ្ធ គឺគេយកដីខ្សាច់មកចាក់គរ ហើយពូនឲ្យមានរូបជាចេតិយឡើង ហៅតាមភាសាបាលីថា "វាលុក-ចេតិយ" តែអ្នកផងតែងហៅជាភាសាខ្មែរថា "ពូនភ្នំខ្សាច់" ព្រោះគំនរខ្សាច់ដែលពូនឡើងនោះមានស្ថានភាពប្រហែលភ្នំ ។

វាលុកចេតិយនេះ មានគតិនិយមថា ធ្វើឡើងដើម្បីឧទ្ទិសថ្វាយជាសក្ការបូជាដំណាងព្រះចូឡាមណីចេតិយ នៅស្ថានត្រៃត្រិង្សសួគ៌ដែលពួកទេវតាសាងបញ្ចុះព្រះកេសធាតុ (ព្រះកេសា) និងព្រះទាឋាធាតុ (ព្រះចង្កូមកែវ) នៃព្រះសម្មាសម្ពុទ្ធ ដោយសំគាល់ថាបានផលានិសង្សណាស់ ។

ការកសាងវាលុកចេតិយ នៅប្រទេសកម្ពុជាយើង មានធ្វើតាំងព្រះពជាតាំងប្រជាកស្ត្រ, តាំងពីរបែបនេះ មានទំនៀមនិងរបៀបព្រម

ទាំងពិធីប្រហែលគ្នា គ្រាន់តែទំនៀមខាងព្រះរាជាជាផ្លូវការ ហៅថា “ព្រះរាជពិធី” ឧឡារិកអធិកអធំជាងពិធីរាស្ត្រ ។ របៀបធ្វើជាផ្លូវការតែងធ្វើនៅវត្តភ្នំដូនពេញ និងព្រះវិហារព្រះកែវមរកត ដូចក្នុង គ.ស. ១៩៥៤ នេះ ធ្វើនៅវត្តភ្នំដូនពេញនៅថ្ងៃទី ៥ និងទី ៦ មេសា, ធ្វើនៅព្រះវិហារព្រះកែវមរកត នៅថ្ងៃទី ៨ និងទី ៩ មេសា ។ ព្រះរាជពិធីនេះមានពិស្តារក្នុងសៀវភៅព្រះរាជពិធីទ្វាទសមាសភាគ ១ ដែលក្រមជំនុំទំនៀមទម្លាប់រៀបរៀងបោះពុម្ពហើយ មានផ្សាយនៅពុទ្ធសាសនបណ្ឌិត្យ ។

ក្នុងទីនេះ សូមពណ៌នាដោយសង្ខេបនូវពិធីរាស្ត្រ ដូចតទៅនេះ:

វាលុកចេតិយ គេតែងសាងនៅទីណា? មានខ្នាតប៉ុណ្ណា? មានទ្រង់ទ្រាយដូចម្តេច? សាងម្តងៗ មានប៉ុន្មានតួចេតិយ? មានគ្រឿងប្រកបដូចម្តេច?

តាមបែបដើម ឃើញថា ឥតមានកំណត់ឲ្យសាងនៅទីណាទេ, តែបើតាមទម្លាប់ដែលបុរាណបណ្ឌិតធ្លាប់ធ្វើមក គឺធ្វើនៅទីណាដែលមានដីខ្សាច់ល្អ ហើយបើតាមទំនៀមទម្លាប់របស់ប្រទេសកម្ពុជាយើង គេច្រើនធ្វើនៅទីវត្ត ដោយទីនេះជាទីប្រជុំជនផង ដើម្បីនឹងឲ្យបានដីចូលវត្តផង, ឯទីដទៃក្រៅពីទីនេះ ដូចនៅដើមពោធិ៍ជាទីសក្ការបូជារបស់ប្រជាជនជាដើមក៏មានធ្វើខ្លះដែរ តែធ្វើដោយតិច ៗ

គេសាងក្នុងវេលាណា?

តាមរឿងព្រេងដើម មានរឿងខ្លះកំណត់ថាត្រូវសាងគឺធ្វើនៅវេលាចូលឆ្នាំ" រឿងខ្លះគ្រាន់តែណែនាំឲ្យធ្វើ ឥតមានកំណត់កាលវេលា, តែតាមទំនៀមរបស់ខ្មែរយើងតែងធ្វើឡើងទាំងស្រុកក្នុងវេលាចូលឆ្នាំ គឺបីថ្ងៃចូលឆ្នាំ ៣ ថ្ងៃក៏មាន មុនឬក្រោយថ្ងៃចូលឆ្នាំបន្តិចបន្តួចដែលរួមហៅថា "រដូវចូលឆ្នាំ" ក៏មាន, ក្រៅពីរដូវនេះគេធ្វើចំពោះពេលបុណ្យចម្រើនអាយុដើម្បីឲ្យបានអាយុយឺនយូរ និងចំពោះពេលដែលមាតាឬបិតាឈឺធ្ងន់ ដើម្បីរំដោះគ្រោះ, ពីពេលខាងក្រោយនេះមានធ្វើតែចំពោះឯកជនតាមពេលដែលមានការជាការចាំបាច់ មិនមែនមហាជនធ្វើទាំងស្រុកទេ, បើរដូវចូលឆ្នាំនោះ គេធ្វើឡើងទាំងប្រទេស ។

គេសាងមានខ្នាត ទំហំ ឬកំពស់ប៉ុណ្ណា?

វាលុកចេតិយគ្មានត្រាណាមួយកំណត់ខ្នាតជាកម្រិតថា ទំហំឬកំពស់ដូចម្តេចទេ ស្រេចនៅលើអធ្យាស្រ័យរបស់អ្នកសាងចង់ធ្វើប៉ុណ្ណាក៏បាន; ហេតុនេះ បានជាឃើញគេធ្វើខ្នាតតូចៗ ប៉ុនពានគោមប្រតិស្ឋានលើតុឬថាសចំពោះពេលរំដោះគ្រោះក៏មាន; ខ្នាតកណ្តាលទំហំមូលចំនួន ២-៣ ហត្ថ កំពស់ត្រឹមបង្កើះក៏មាន; ខ្នាតធំៗប៉ុនជង្រុកស្រូវមានភាពប្រហែលដំបូកធំឬកូនភ្នំក៏មាន ។

តាមដែលបានសង្កេតមក ខ្នាតតូចៗដាក់លើតុឬថាសគេធ្វើចំពោះឯកជនដែលធ្វើរំដោះគ្រោះនៅពេលដែលគេមានជម្ងឺធ្ងន់; ខ្នាតកណ្តាលនិងខ្នាតធំៗ គេធ្វើឡើងទាំងប្រទេសនៅរដូវចូលឆ្នាំ ។

គេសាងស្តូបៗ ចំនួនប៉ុន្មានតួចេតិយ?

ពាលុកចេតិយ គ្មានតម្រាណាមួយកំណត់បរិមាណថាចំនួនប៉ុន្មានទេ, តែតាមទំនៀមនៅប្រទេសកម្ពុជាយើង បើដើម្បីរំដោះគ្រោះចំពោះឯកជនដែលធ្វើតាមគ្រឹះស្ថានរបស់ខ្លួន ឃើញគេធ្វើតែមួយក៏មាន ដល់ ៣ ឬ ៥ ក៏មាន ហើយគេធ្វើតូចៗ ដាក់លើតុ ឬថាសដូចបរិយាយពីខាងដើម ការដែលធ្វើតែមួយ ឬធ្វើដល់ ៣ ឬ ៥ នោះសោត ក៏ឥតមានតម្រាណាមួយនិយាយដល់ គឺស្រេចនៅលើអធ្យាស្រ័យអ្នកធ្វើ បើធ្វើនៅទីវត្ត ឃើញគេធ្វើព័ទ្ធជុំវិញព្រះវិហារតាមទិសទាំង ៨, តែចួនកាលឃើញគេធ្វើនៅទីសមគួរណាមួយ ក្នុងវត្តតែចំនួន ៥ ចេតិយក៏មាន គឺធ្វើមួយធំខ្ពស់ចំកណ្តាល (ដែលតាមចាស់ៗ និយមថាធ្វើដំណាងភ្នំសិនេរុ ដែលជាទីតាំងឋានតែត្រិង្ស), តូចៗ បួន នៅទិសទាំង ៤ គឺទិសបូព៌ា ទក្សិណ បស្ចិម ឧត្តរ (ដំណាងភ្នំយុគន្ធរដែលជាទីតាំងឋានចាតុម្មហារាជិកា) ។

គ្រឿងប្រកបពាលុកចេតិយដូចម្តេចខ្លះ?

តាមទំនៀមខ្មែរយើង កាលបើគេជញ្ជូនដីខ្សាច់មកចាក់គរពូនឲ្យមានទ្រង់ទ្រាយប្រហែលភ្នំ មានកំពស់ទទឹងទំហំធួនល្មមតាមដែលគេត្រូវការហើយ គេច្រើនយកកក្អមមួយកំណាត់ ឬយកក្អមទាំងមូលមកកប់ឲ្យនៅត្រឹមកដាក់ត្រង់កំពូល គ្រប់ចេតិយ ឲ្យមានសណ្ឋានដូចក្បាច់ក

ចេតិយមែនទែន. វត្តខ្លះដែលគេរកដីខ្សាច់ពុំបានហើយគេបង់ឲ្យបម្រើនដី វត្តគេយកដីកណ្តាលធ្វើជំនួសក៏មាន ធ្វើហើយគេធ្វើកជរ៉ែតព័ទ្ធជុំវិញពីក្រៅចេតិយទាំងនោះ ទុកតែមាត់ទ្វារចេញចូល ៤ ទិស គេធ្វើរានទេវតា ៨ ដាក់គ្រប់ ៨ ទិស មានរានមួយទៀតគេសន្មតជារានព្រះកាល ឬព្រះយមរាជដាក់នៅទិសបូព៌ មានទាំងឆត្រ នឹងទង់រលកដោតគ្រប់រានទាំងនោះផង ព្រមទាំងបូជាដោយផ្កាភ្ញី នឹងស្លាធម៌ទឹកអប់ជាដើម ។

កាលគេធ្វើគ្រឿងប្រដាប់ដូចរៀបរាប់ខាងលើនេះរួចហើយ វេលាថ្ងៃរសៀលទាបគេយកទៀនធូបទៅអុជ យកផ្កាឈើមានពណ៌ផ្សេង ៗ ទៅដោតដាក់បូជានឹងយកទង់ធ្វើពីក្រដាសពណ៌ផ្សេងៗ ទៅដោតបូជានៅកំពូលវាលុកចេតិយទាំងនោះ ហើយមានអាចារ្យម្នាក់នាំឧបាសកឧបាសិកាដើរប្រទក្សិណ ៣ ជុំរួចនមស្ការព្រះរតនត្រ័យ សមាទានសីល ហើយយកសំពត់សទៅព័ទ្ធឈៀង ដូចអង្រ្កតពីលើវាលុកចេតិយទាំងនោះ រួចនាំសូត្រអធិដ្ឋានវាលុកចេតិយទាំងអស់ ដែលគេហៅតាមសំដីអ្នកស្រុកថា "បំបួសភ្នំ" ឲ្យជាដំណាងព្រះចូឡាមណីចេតិយឯឋានត្រៃត្រឹង្សសួគ៌ ដោយបាលីថា ឥមំ វាលុកចេតិយំ ចុឡ្ឡាមណិចេតិយំ អធិដ្ឋាមិ (ប្រែថា) "ខ្ញុំសូមតាំងចិត្តអធិដ្ឋានព្រះចេតិយខ្សាច់នេះ ឲ្យជារបស់ដំណាងព្រះចូឡាមណីចេតិយ" ។

ក្រោយពេលបំបួសភ្នំ, វេលាយប់គេនាំគ្នាចូលវិហារឬសាលាបុណ្យ និមន្តព្រះសង្ឃសូត្រព្រះបរិត្ត រួចទេសនាសាស្ត្រាអានិសង្សខ្សាច់ បើបុណ្យនោះគេធ្វើត្រូវលើថ្ងៃចូលឆ្នាំ លុះចប់ទេសនា គេលេងល្បែងផ្សេង ៗ តាមទម្លាប់ស្រុករបស់គេ មានលេងឈូង អង្គុញ ទាញព្រ័ត្រ ច្រៀងកញ្ចាជាដើម, វេលាព្រឹកគេអង្គាសយាគូ ថ្ងៃត្រង់អង្គាសភត្តប្រគេនព្រះសង្ឃទូទៅទាំងវត្តគ្រប់បីថ្ងៃបីយប់, នៅថ្ងៃគម្រប់ ៤ គេនិមន្តព្រះធម្មកថិកទេសនាសង្គាយទាក់ទងបុណ្យ ហើយនិមន្តលោកបង្សុកូល រួចប្រគេនរណ្ដាប់ទេយ្យទានមានសំពត់សាដកឈើគូសបារីស្ករតែជាដើមចំពោះព្រះសង្ឃតាមសមគួរដល់សទ្ធា ជាការសម្រេចពិធីបុណ្យសាងវាលុកចេតិយ ត្រឹមប៉ុណ្ណេះ ។

តាមទំនៀមវាលុកចេតិយដែលគេបានអធិដ្ឋាន ( បំបួស ) ហើយគេកាន់ថាបានឡើងពេញជាពុទ្ធចេតិយមែនៗ នរណាមួយទៅរំលាយព្រះចេតិយនោះមុនគេផ្សឹកចេញ គេទុកថាជាមានទោសធ្ងន់ណាស់, ដោយហេតុនេះ កាលគេធ្វើបុណ្យរួចហើយ អាចារ្យក៏ផ្សឹកចេញភ្លាមដោយភាសាបាលីថា ឥមំ វាលុកចេតិយំ បច្ចក្ខាមិ (ប្រែថា) "ខ្ញុំផ្សឹកឥឡូវនេះនូវវាលុកចេតិយនេះ គឺដកចិត្តចេញលែងកាន់ថាជាវាលុកចេតិយហើយ" ។ ក្រោយពីនោះទោះនរណារំលាយក៏គ្មានទោសពៃរ៍អ្វីទេ ហើយគេយកដីខ្សាច់ភ្នំនោះទៅស្ថាបនាជាវត្ថុអ្វី ៗ ក្នុងវត្តតាមត្រូវការ ។

មានសូត្រមួយឈ្មោះមហាសំការសូត្រ សំដែងពីដើមកំណើតរឿងបុណ្យសាងព្រះចេតិយថាបានផលានិសង្សណាស់ មានសេចក្តីដូចស្រង់មកដោយសង្ខេបតទៅនេះថា:

សម័យមួយ ព្រះបរមសាស្តាទ្រង់ប្រថាប់ក្នុងវត្តជេតពន ទ្រង់សំដែងឆ្លើយប្រស្នាព្រះបាទបសេនទិកោសលថា: មហាបពិត្រ! អ្នកដែលបានសាងព្រះចេតិយបានបូជាព្រះចេតិយ ដោយវត្ថុផ្សេងៗ មានផ្កាក្តី គ្រឿងក្រអូបទឹងទៀនធូបជាដើមបានផលច្រើន តែងបានទៅកើតក្នុងត្រកូលក្សត្រត្រកូលព្រាហ្មណ៍ ។ល។

អ្នកដែលបានដោះលែងសត្វក្នុងទុកាសសង្គ្រានចូលឆ្នាំថ្មី រមែងមានអាយុយឺនយូរមានសេចក្តីសុខច្រើន អ្នកណាបានផ្តល់ទឹកមាតាបិតាគ្រូឧបជ្ឈាយ៍អាចារ្យក្តី បានរក្សាសីលក្តី ឲ្យទានក្តី បានអុជប្រទីបផ្កាលាក្តី បានដោតទង់បូជាក្តី បានជីកស្រះក្តី បានសង់ស្ពានក្តី បានធ្វើផ្លូវថ្នល់ក្តី ។ល។ ព្រះចតុលោកបាលតែងកត់ឈ្មោះអ្នកនោះទុកលើផែនមាស, បើអ្នកណាមិនស្គាល់គុណព្រះពុទ្ធព្រះធម៌ព្រះសង្ឃ មិនធ្វើបុណ្យ ធ្វើតែបាប ព្រះចតុលោកបាល តែងតែកត់ឈ្មោះអ្នកនោះទុកលើស្បែកឆ្កែ ។ល។

ក្រៅពីមហាសំការសូត្រដែលថ្លែងមកខាងលើនេះ មានរឿងនិទាន២ទៀតសុទ្ធតែនិយាយពីដើមកំណើត នៃការកសាងព្រះចេតិយខ្សាច់ផង គឺ

និទានទី ១ ដំណាលពីព្រះពោធិសត្វនាមបុរិកៈ ជាឈ្មួញសំពៅ បើកសំពៅទៅជួញបានឃើញផ្នូកខ្សាច់ល្អនៅឆ្នេរសមុទ្ទ ក៏បបួលពាណិជឯទៀត កសាងជាវាលុកចេតិយ ឧទ្ទិសជាដំណាងព្រះចូឡាមណីចេតិយនៅឋានត្រៃត្រឹង្សសួគ៌ ដែលបញ្ចុះព្រះកេសានិងព្រះចង្កូមកែវនៃព្រះសម្មាសម្ពុទ្ធ បានបេះផ្កាឈើបូជា បានដើរប្រទក្សិណ ៣ ជុំ ហើយបើកសំពៅចេញទៅ ។ លុះបុរិកពោធិសត្វនិងឈ្មួញទាំងនោះរំលាងបញ្ចក្ខន្ធទៅបានទៅកើតជាទេវបុត្រនៅឋានសួគ៌ច្រើនជាតិ ច្យុតពីឋានសួគ៌មកកើតជាស្តេចចក្រពត្តិ ជាស្តេចឯករាជ្យច្រើនជាតិ, ទីបំផុតបុរិកពោធិសត្វបានត្រាស់ជាព្រះពុទ្ធ, ឈ្មួញឯទៀតបានជាពុទ្ធសាវ័កដោយអំណាចផលដែលបានសាងវាលុកចេតិយនោះឯង ។

និទានទី ២ ដំណាលថានេសាទម្នាក់ សម្លាប់សត្វចិញ្ចឹមជីវិតតាំងពីក្មេងរហូតដល់ចាស់មិនដែលធ្វើបុណ្យម្តងសោះ, ថ្ងៃមួយកំពុងតែលីលំពែង ស្ពាយបាយកញ្ចប់ចេញទៅព្រៃស្វែងរកសត្វ មានភិក្ខុ ១ រូបសុំបង្ហាន់, ដោយលោកទទូចសុំមិនលែងសោះ នេសាទក៏ពូតបាយ ១ ពំនូតប្រគេនទៅ ។ លុះនេសាទស្លាប់ទៅត្រូវពួកយមបាលចាប់ខ្លួនទៅសួរពីរឿងធ្វើបុណ្យបាបកាលនៅជាមនុស្ស, នេសាទតបថាមិនបានធ្វើបុណ្យសោះ ធ្វើតែបាប យមបាលក៏ចាប់នេសាទបោះទៅក្នុងភ្លើងនរក, នេសាទក្រឡេកឃើញភ្លើងសម្បុរដូចត្រៃចីវរ ក៏នឹកដល់ទាន

របស់ខ្លួនទើបឆ្លើយប្រាប់ថា កាលខ្លួននៅជាមនុស្សបានធ្វើទានបាយ ១ ពំនូតដល់ភិក្ខុ ១ រូបដែរ ។ យមបាលប្រាប់ថា បើដូច្នោះអ្នកឯងត្រូវបានឡើងទៅកើតឯឋានសួគ៌ ៧ ថ្ងៃ, ដល់ថ្ងៃទី ៨ យើងនឹងយកអ្នកឯងមកទម្លាក់នរកវិញ ។ នេសាទក៏បានទៅកើតឯឋានសួគ៌ ឈ្មោះ អន្នលោកកន្ទ្រិនីទេវបុត្រ មានវិមាន មានបរិវារ មាននាងសុវណ្ណទេវីជាទេពី ។ អន្នលោកកន្ទ្រិនីទេវបុត្រសោយសុខបាន ៦ ថ្ងៃ នឹកដល់ពាក្យយមបាលក៏ទោមនស្ស ចូលទៅដេកយំ, នាងសុវណ្ណទេវីសួរក៏ប្រាប់តាមដំណើរ, នាងថា បើដូច្នេះយើងត្រូវសាងព្រះលុកចេតិយ ហើយធ្វើបុណ្យឆ្លងទើបរួចបាតកម្មពៀរនោះ ។ អន្នលោកកន្ទ្រិនីទេវបុត្រក៏បាត់ការកសាងព្រះលុកចេតិយស្រេចក្នុងថ្ងៃទី ៧ ។

ដល់ថ្ងៃទី ៨ ពួកយមបាលទៅរក, នាងសុវណ្ណទេវីប្រាប់ថា ស្វាមីយើងបានសាងព្រះលុកចេតិយបានធ្វើបុណ្យឆ្លង បានរួចស្រឡះបាតកម្មពៀរហើយ, បើអ្នកនៅតែត្រូវការយកខ្លួនទៅធ្វើទោសទៀតចូរអ្នកកាប់គ្រាប់ខ្សាច់ ១ ពែងនេះសិនបើកាប់អស់ទើបយកទៅបាន ។ ពួកយមបាលក៏កាប់តាំងពីព្រឹកដល់ថ្ងៃត្រង់ គ្រាប់ខ្សាច់ដែលកាប់ហើយដាក់ក្រៅពែងកំពស់ប៉ុនភ្នំ ក្នុងពែងនៅតែពេញដដែល ពួកយមបាលបាញ់បំណោះក៏ត្រឡប់ទៅយមលោកវិញ ។ អន្នលោកកន្ទ្រិនីទេវបុត្របាននៅក្នុងឋានសួគ៌ជាបមក ដោយអំណាចអានិសង្សកសាងព្រះលុកចេតិយនោះឯង ។

និទានទី ៣ ដំណាលថា មានក្មេងម្នាក់បេះតែទៅពូនក្អំខ្សាច់លេង នៅផ្លូវខ្សាច់ក្បែរផ្ទះដោយតាំងចិត្តជាបុណ្យតាមនិស្ស័យក្មេង ពូនហើយដកនទៀលដីខ្សាច់ក្បែរក្អំនោះរាល់ថ្ងៃ ទាល់តែអ្នកស្រុកគេហៅក្មេងនោះថា "ចៅកំជិលខ្សាច់" ។

ថ្ងៃមួយ ព្រះឥន្ទ្របើកទិព្វចក្ខុមកឃើញចៅកំជិលខ្សាច់ពូនក្អំខ្សាច់ ក៏ចាត់ឲ្យនាងទេពធីតា ១ រូបមកធ្វើជាភរិយា, តាំងពីបានភរិយាហើយ ចៅកំជិលខ្សាច់មានខ្លួនប្រាណស្អាតបាត មានកិត្តិសព្ទល្បីល្បាញថា ចៅកំជិលខ្សាច់បានប្រពន្ធល្អណាស់ ។ ទន្ទឹមវេលានោះព្រះរាជាម្ចាស់ផែនដី ទ្រង់ព្រះទិវង្គត គ្មានព្រះរាជបុត្រគងរាជសម្បត្តិ ពួកសេនាបតីគិតឃើញថា ចៅកំជិលខ្សាច់គួរធ្វើព្រះរាជា ក៏ចាត់ការផ្សេងបុស្សរថ (រថផ្កា) រកអ្នកមានបុណ្យ បុស្សរថរត់ទៅត្រង់លើចៅកំជិលខ្សាច់ ទើបគេនាំគ្នាអញ្ជើញទៅសោយរាជ្យ អភិសេកនាងទេពធីតាជាអគ្គមហេសី ។

សូត្រនិងនិទានខាងលើនេះ សុទ្ធតែជាសាស្ត្រស៊ូត្រគេជាគម្ពីរតែង ឡើងខាងក្រោយ, មហាសំការសូត្រកាសាបាលី និទានទាំង ៣ សម្រាយភាសាខ្មែរ អ្នកផងតែងហៅនិទានទាំងនោះថា "សាស្ត្រអានិសង្សខ្សាច់", សាស្ត្រទាំងនោះបើមិនមួយក៏មួយធម្មកថិកច្រើនយកមកទេសនានៅពេលធ្វើបុណ្យកសាងវាលុកចេតិយ ព្រោះហេតុនេះទើប

ខ្មែរយើងទើបមានសទ្ធាជ្រះថ្លានាំគ្នាធ្វើបុណ្យនេះជាប់ជាប្រពៃណីរៀងមក ដរាបដល់សព្វថ្ងៃនេះ ។

បណ្ដាសូត្រនិងនិទាន ដែលមាននិយាយពីការកសាងភ្នំលុកចេតិយ ទាំងប៉ុន្មាន ដូចបានស្រង់មកថ្លែងដោយសង្ខេបខាងលើនេះ មហាសំការ សូត្រ និទានបារីកពោធិសត្វ និងទិទានទៅកំដិលខ្សាច់គ្រាន់តែសំដែង ថា ពូនភ្នំខ្សាច់បានផលានិសង្សច្រើន, ចំណែកនិទាននេសាទថា ពូនភ្នំខ្សាច់ផ្ដាច់កម្មពៀរ, ព្រោះហេតុនេះបានជាជនសាម័ញ្ញនិយមជឿ តាមនិទាននេសាទថា ពូនភ្នំខ្សាច់ផ្ដាច់បាប; តែសម្រាប់ជនជាបណ្ឌិត ដែលយល់ការណ៍ពិតតាមគោលពុទ្ធវចនៈ មិននិយមដូច្នោះទេបើពូនភ្នំ ខ្សាច់ក៏ពូនឧទ្ទិសថ្វាយជាតំណាងព្រះចូឡាមណីចេតិយត្រង់ៗ យកផលា-និសង្សដើម្បីបានសេចក្ដីសុខ សេចក្ដីចម្រើនក្នុងលោកនេះ និងលោក ខាងមុខ ។

បរិយាយពីទំនៀមសាងភ្នំលុកចេតិយ (ពូនភ្នំខ្សាច់) ចប់ដោយ សង្ខេបត្រឹមប៉ុណ្ណេះ ។

---

# ពិធីបុណ្យបញ្ចុះបឋមសិលា

# នៅទីស្ថានពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ

ពុទ្ធសាសនបណ្ឌិត្យ

---

កាលពីថ្ងៃទី ២៤ ខែមីនាឆ្នាំ ១៩៥៤ មានធ្វើពិធីបុណ្យបញ្ចុះបឋមសិលាចារិក នៅកន្លែងស្ថាបនា "ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ" ជាមហាវិទ្យាល័យខាងពុទ្ធសាសនា សម្រាប់ព្រះសង្ឃឬគ្រហស្ថសិក្សាវិជ្ជាជាន់ខ្ពស់ថ្នាក់បណ្ឌិត នៅក្រោមអធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ក្រសួងធម្មការជាអ្នកចាត់ចែង ។ ចាប់ធ្វើតាំងពីយប់ថ្ងៃអង្គារទី ២៣ រហូតដល់ពេលព្រឹកថ្ងៃទី ២៤ មីនា ទើបបានបញ្ចប់ ។

នៅរាត្រីថ្ងៃទី ២៣ មីនានោះ មានការជួបជុំព្រះសង្ឃចំនួន ៥០០អង្គ និងពុទ្ធបរិស័ទជាង ២០០០ នាក់ បាននិមន្ត អញ្ជើញទៅសំដែងសេចក្ដីត្រេកអរចំពោះសំណង់នៃគ្រឹះស្ថាននេះ ។ ម៉ោង ៨ យប់ ព្រះសង្ឃបានចំរើនព្រះបរិត្តក្នុងបាពាំនៅកន្លែងដែលកសាង រួចនិមន្តសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ សំដែងធម៌ ដែលជាហេតុញុំាងចិត្តពុទ្ធបរិស័ទទាំងឡាយ ឲ្យរីតតែមានសេចក្ដីជ្រះថ្លា យ៉ាងក្រៃលែង ។ បន្ទាប់មក មានភាពយន្ត (កុន) បញ្ចាំងជូនប្រជាជនមើលជាទីកំសាន្ត ។

ព្រឹកឡើងថ្ងៃទី ២៤ ចាប់តាំងពីម៉ោង ៨,៣០ នាទី ទៅដល់ម៉ោង ៨, ៥០ នាទី ឥស្សរជនទាំងឡាយ ទាំងបព្វជិត ទាំងគ្រហស្ថ មានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ, សម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សាវត្តលង្កា, ព្រះពោធិវង្សហួត-តាតបាងហ្វាងសាលាបាលីជាន់ខ្ពស់ និងរាជាគណៈឋានានុក្រម, ចំណែកគ្រហស្ថមានឯកឧត្តមចាន់-ណាក នាយករដ្ឋមន្ត្រី, ឯកឧត្តមប៉ែន-នុត អតីតរដ្ឋមន្ត្រីទី ១, សមាជិករដ្ឋាភិបាល, ឯកឧត្តមយិត-ស៊ីន ប្រធានក្រុមប្រឹក្សាជាតិ, លោកគ្លារ្យជាហ្វូត៌កុម៉ែស្យេរស៊ូទី, អគ្គទូត, ឯកឧត្តមហ៊ុយ-កន្ធុល អតីតនាយករដ្ឋមន្ត្រី និងអតីតរដ្ឋមន្ត្រីដទៃទៀតជាច្រើនរូប ព្រមទាំងនាយកមន្ទីរ នាយក្រុមរាជការជាច្រើនតំណែង បាននិមន្ត-អញ្ជើញទៅជាឧត្តមមង្គលក្នុងពិធីបុណ្យនេះ ។

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលមានក្រុមប្រឹក្សាឯកជនអមព្រះអង្គទាំងពីររូប, រាជង្គរក្ស, លេខាធិការផ្ទាល់ព្រះអង្គហែហមផង បានស្តេចយាងទៅដល់កន្លែងសង់គ្រឹះស្ថានមហាវិទ្យាល័យ នៅម៉ោង ៨, ៥៥ នាទី ។ ក្នុងពេលដែលស្តេចយាងចុះពីព្រះទីនាំងរថយន្ត គណៈរដ្ឋមន្ត្រីបានរង់ចាំក្រាបថ្វាយបង្គំទទួល ត្រង់ចិញ្ចើមតិរវិថីស៊ីសុវត្ថិ ។ នៅទីនោះមានក្រុមទាហានរក្សាព្រះអង្គ និងក្រុមភ្លេងព្រះរាជទ្រព្យឈរជាពីរជួរចាំធ្វើគារវកិច្ច និងប្រគំភ្លេងបទនគររាជជាទីកិត្តិយសចំពោះព្រះរាជដំណើរ ដែលស្តេចយាងមកដល់ ហើយបន្ទាប់មកទើបព្រះមហាវីរៈ

ក្សត្រិយ៍ យាងចូលទៅប្រថាប់នៅក្នុងបាំមួយ ដែលវិចិត្រដោយទង់ជាតិ ទង់សាសនានិងស្លឹករុក្ខជាតិជាគ្រឿងលំអ ។

ក្នុងពេលនោះ ឯកឧត្តម សម-ញាណ រដ្ឋមន្ត្រីក្រសួងធម្មការ សិល្បការ និងស.សទសិក្សាធិការ បានសំដែងនូវមនោភាពដ៏សម្ប-យុត្តដោយសោមនស្សចេតនា និងបីតិប្រាមោជដ៏ក្រៃលែង ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, ចំពោះសម្តេច, លោកហូត៍កុម៉ីស្ស៊ែរ, ឯកឧត្តមនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីទាំងឡាយ ព្រមទាំងទ្រង់ និង ឯកឧត្តមជាអគ្គទូត ដែលបានស្តេចយាង-និមន្ត-អញ្ជើញមកជួបជុំជា មហាសន្និបាតក្នុងពិធីបុណ្យនេះ ដែលទុកជាកិត្តិយសមួយដ៏ប្រសើរ និងជាមង្គលសួស្តីមួយដ៏ឧត្តម សមដល់កិច្ចការដែលទាក់ទងនឹងព្រះពុទ្ធ-សាសនាជាទីគោរពរបស់ប្រជាជនក្នុងប្រទេស ។ ហើយឯកឧត្តមសូមព្រះរាជទានឱកាសបន្តិច ដើម្បីថ្លែងសុន្ទរកថា រៀបរាប់នូវមូលហេតុនៃការកសាងមហាវិទ្យាល័យនេះដោយសង្ខេប ដូចតទៅនេះ ។

ការសិក្សាខាងព្រះពុទ្ធសាសនា ក្នុងប្រទេសកម្ពុជានេះ បានកើតឡើងតាំងពីឆ្នាំ ១៩១៤ ចំនួន ៤០ ឆ្នាំមកហើយគឺសាលាបាលីជាន់ខ្ពស់នេះឯង ជាសាលាតែមួយ ឋិតនៅក្នុងសេចក្តីឧបត្ថម្ភរបស់ព្រះរាជរដ្ឋា-ភិបាល ។ ឯសាលាបាលីរង់បានកើតមានឡើងតាំងពីឆ្នាំ ១៩៣៣ ឋិតនៅក្នុងសេចក្តីឧបត្ថម្ភរបស់លោកចៅអធិការវត្ត ព្រមទាំងពុទ្ធបរិស័ទ

ជើងវត្ត រាជការគ្រាន់តែទទួលស្គាល់ហើយនឹងជួយចាត់ការឲ្យមានរបៀបរៀនសូត្រ នឹងការប្រឡងចេញពីសាលាប៉ុណ្ណោះ ។ សាលាបាលីរងនោះ កើតឡើង ២១ ឆ្នាំហើយមានចំនួន ៣៥១ ទាំងក្នុងក្រុងនិងខែត្រក្រៅ បព្វជិតដែលសិក្សាក្នុងសាលាបាលីរង បានគ្រប់ ៣ ឆ្នាំ ត្រូវប្រឡងចេញបានទទួលវិញ្ញាបនប័ត្រ ១ ជាសំគាល់ ហើយមានអំណាចប្រឡងចូលរៀន ក្នុងសាលាបាលីជាន់ខ្ពស់បាន សព្វថ្ងៃនេះមានកាន់តែច្រើនឡើងៗ ដូចក្នុងឆ្នាំ ១៩៥៣ និង ១៩៥៤ នេះ ឃើញមានបព្វជិតដល់ទៅ ២.០០០ រូប មកប្រឡងដណ្ដើមយកកន្លែងរៀនក្នុងសាលាបាលីជាន់ខ្ពស់ ដែលមានតែ ១០០ កន្លែង ឃើញត្រូវនៅសល់ ១ ៩០០ រូប ។

សាលាបាលីជាន់ខ្ពស់សព្វថ្ងៃនេះ ពុំអាចនឹងចាត់ការឲ្យចំរើនជាងនេះទៅទៀតបានទេ ព្រោះខ្វះទីកន្លែងរៀន ខ្វះគ្រូបង្រៀន ។ ម្យ៉ាងទៀត សិស្សដែលបានទទួលសញ្ញាប័ត្រពីសាលានេះហើយ ឥតមានមហាវិទ្យាល័យបន្តចំណេះវិជ្ជាជាន់ខ្ពស់ទៅទៀត ម្ល៉ោះហើយឃើញថាពួកបព្វជិតក្នុងប្រទេសក៏ឋិតនៅក្នុងឋានៈ ជាអ្នកមានចំណេះពុំទាន់គ្រប់គ្រាន់ គឺថាពួកបព្វជិតជានិស្សិតទាំងនេះ មានចំណេះវិជ្ជា គ្រាន់តែអាចបំពេញកិច្ចការខាងព្រះពុទ្ធសាសនា សម្រាប់ប្រទេសរបស់ខ្លួនប៉ុណ្ណោះ មិនអាចនឹងផ្សាយព្រះពុទ្ធសាសនា ពីប្រទេសរបស់ខ្លួនទៅនានាប្រទេសបានឡើយ ទាំងពុំអាចនឹងទៅបំពេញមុខការ ប្រស្រ័យខាងផ្លូវសាសនា

ជាមួយនឹងពុទ្ធសាសនិកជន ក្នុងនានាប្រទេសបានទៀត ដោយហេតុមកពីពុំបានចេះភាសាបរទេសឲ្យល្មមគ្រប់គ្រាន់ ។ ការខ្វះខាតយ៉ាងនេះនាំឲ្យពួកបព្វជិតជានិស្សិត ខ្វះសេចក្ដីអង់អាចខ្វះគំនិតដែលត្រូវគិតធ្វើឲ្យព្រះពុទ្ធសាសនាបានចំរើនរីកពីធម្មតា ហើយថែមទាំងខ្វះយោបល់ដ៏ថ្លៃថ្លាផងទៀត ។

អាស្រ័យហេតុដូចខាងលើនេះហើយ ទើបព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់ជាអគ្គសាសនូបត្ថម្ភ ក៏ទ្រង់សព្វព្រះរាជហឫទ័យនឹងពង្រីកការសិក្សាខាងព្រះពុទ្ធសាសនា ឲ្យបានធំទូលាយឡើង ឲ្យសមតាមកាលៈទេសៈ នៃប្រទេសឯករាជ្យ ទើបទ្រង់មានព្រះរាជបញ្ជាមកក្រសួងធម្មការ ឲ្យពិនិត្យមើលហើយចាត់ការរៀបចំពង្រីកការសិក្សាឲ្យបានចំរើនឡើង ។

ក្រសួងធម្មការ បានទទួលព្រះបរមរាជឧង្ការ ហើយចាត់ការតាំងគណៈកម្មការមួយក្រុមនឹងអនុគណៈកម្មការ ១ ក្រុម ដើម្បីរៀបចំរបៀបរៀនក្នុងសាលាបាលីជាន់ខ្ពស់ ព្រមទាំងរៀបចំបង្កើតឲ្យមានការសិក្សាថ្នាក់ខ្ពស់ឡើងទៀត គឺបង្កើតឲ្យមានមហាវិទ្យាល័យខាងព្រះពុទ្ធ-សាសនា ហៅថា "ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ" ។

ក្នុងកិច្ចពង្រីកការសិក្សានេះ ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូងទ្រង់បានសម្រេចឲ្យយកទីដីនេះ គឺដីដែលមានគោលស៊ីម៉ងត៍ព័ទ្ធជុំវិញ

នេះហើយ ដែលទុកជាមហាវិទ្យាល័យខាងព្រះពុទ្ធសាសនា ។ ហើយទ្រង់បានបរិច្ចាគព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ១ សែនរៀលសម្រាប់កសាងព្រមទាំងស្តេចយាងមកជាព្រះរាជាធិបតីភាព ក្នុងពិធីបុណ្យបញ្ចុះបឋម-សិលា នាថ្ងៃសុភមង្គលនេះ ទុកជាព្រះមហាករុណាទិគុណយ៉ាងប្រសើរបំផុត ។

ការរៀបចំបង្កើតមហាវិទ្យាល័យនេះ មានគហបតី ១ នាក់ឈ្មោះ បេ-យាន ជាអ្នកជំនួញ កើតសេចក្ដីជ្រះថ្លាមុនគេ បានទទួលកសាងគ្រឹះស្ថានមួយខ្នងពីឥដ្ឋស៊ីម៉ង់ត៍ មានបណ្ដោយ ២៤ ម៉ែត្រ ទទឹង ១២ ម៉ែត្រ, ត្រង់កន្លែងដីផ្សារស្នួនចាស់ នៅជ្រុងវិថីឧកញ៉ាឈុនទឹងតំរវិថី-ស៊ីសុវត្ថិ ជាខាងជើងសាលាបាលីជាន់ខ្ពស់ ទីដីនេះមានបណ្ដោយ ៨០ ម៉ែត្រនឹងទទឹង ៦០ ម៉ែត្រ ជាព្រះរាជអំណោយនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។

លុះចប់សុន្ទរកថានេះ ព្រះភូមិន្ទទ្រង់ស្តេចយាងទៅប្រតិស្ឋានស៊ី-ម៉ង់ត៍លាយដោយដីខ្សាច់ដកល់លើពានប្រាក់ ដែលមានគហបតីបេ យាន ព្រមទាំងបុត្រាបុត្រីនិងក្រុមញាតិទ្រគោរពថ្វាយ ។ ព្រះមហាក្សត្រិយ៍ទ្រង់យកព្រះហស្តចាប់ស្លាបព្រាបូកវត្ថុធាតុនេះដាក់ទៅក្នុងរណ្ដៅ ស្រេចហើយទើបរំកិលបឋមសិលាបញ្ចុះពីលើ ព្រមទាំងទ្រង់ប្រោសព្រះរាជទានសុគន្ធវារីលើបឋមសិលានេះផង ។

ក្នុងពេលដែលព្រះមហាក្សត្រិយ៍ កំពុងប្រតិស្ឋានបឋមសិលាជានិមិត្តរូបនេះ ព្រះសង្ឃបានស្វាធ្យាយគឺសូត្រជយន្តោប្រសិទ្ធិជោគជ័យជាមួយនឹងព្រះរាជករណីយកិច្ចផង, បន្ទាប់ពីព្រះមហាក្សត្រិយ៍មក សម្តេចព្រះសង្ឃនាយកទាំងពីរគណៈ នឹងសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា សមាជិករដ្ឋាភិបាលព្រះរាជប្រតិភូផ្ទាល់ព្រះអង្គ, ប្រធានក្រុមប្រឹក្សាជាតិ, លោកហូត៌កុម៉ីស្សែរនឹងអង្គទូត បានប្រោះទឹកលើបឋមសិលានេះ តមកទៀត ជាកិច្ចឧប្បត្តិកបង្កបង្កើតមហាវិទ្យាល័យនេះឡើងដាក់នាមថា ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ដើម្បីពង្រីកកិច្ចសិក្សា ខាងព្រះពុទ្ធសាសនា ឲ្យបានរីតតែខ្ពង់ខ្ពស់ សំរាប់សិក្ខាកាមកុលបុត្រ ។

ខាងពុទ្ធសាសនបណ្ឌិត្យ មានសេចក្តីសង្ឃឹមទុកជាមុនថា គង់នៅមានពុទ្ធបរិស័ទ ដែលមានសទ្ធាជ្រះថ្លា ដូចគហបតិបេយានេះ ច្រើនទៀត អាចយល់ប្រយោជន៍ដល់ជាតិ, សាសនា, មហាក្សត្រិយ៍ ជួយស្រោចស្រង់មាតុភូមិឲ្យបានចំរើន ក្នុងពេលដែលទើបនឹងបានឯករាជ្យថ្មី ៗ នេះ ។

ពិធីបុណ្យបញ្ចុះបឋមសិលានេះ បានបញ្ចប់នៅម៉ោង ៩ និង ៣០ នាទី ក្រោយពេលដែលព្រះមហាក្សត្រិយ៍ ស្តេចយាងត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ។

ពុទ្ធសាសនបណ្ឌិត្យ ។